# ធម៌សូធ្យបូជា
# គុណព្រះរតនត្រ័យ
# សង្ខេប




ប្រមូលរៀបចំដោយ

-ភិក្ខុចន្ទប្បញ្ញោ អ៊ឹម ភារុណ



ផ្សាយចេញពីវត្តសុវណ្ណចារមីស្រីជីតារាម ហៅវត្តស្វាកែត

ថ្ងៃវិសាខបូជា ១៥កើត ខែ វិសាខ ព.ស. ២៥៥៩

# ធម៌សូត្របូជា

# គុណព្រះរតនត្រ័យ

# សង្ខេប



**ប្រមូលរៀបចំដោយ**

**-ភិក្ខុចន្ទប្បញ្ញោ អ៊ឹម ឆារុណ**

ផ្សាយចេញពីវត្តសុវណ្ណចារមីស្រីជីតារាម ហៅវត្តស្វាកែត
កាំណែថ្មីបោះពុម្ពលើកទី២
ថ្ងៃវិសាខបូជា ១៤កើត

# អារម្ភកថា

ព្រះសម្មាសម្ពុទ្ធ គឺជាអគ្គបុគ្គលប្រសើរបំផុតនៅលើលោក គ្មានបុគ្គលណាមួយស្មើនឹងព្រះអង្គ ហើយទ្រង់បានត្រាស់សម្តែងថា **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យតែងនាំមកនូវសេចក្តីសុខ ។ ដូច្នេះសូមសាធុសប្បុរសជ្រះថ្លាក្នុងការបំពេញបុណ្យទៅតាមសទ្ធារបស់ខ្លួនឲ្យបានរឿយៗ កុំបីមានការធ្វេសប្រហែសឡើយ ។ សៀវភៅធម៌សូត្របូជាគុណព្រះរតនត្រ័យសង្ខេបនេះ ធ្វើឡើងក្នុងគោលបំណងសម្រាប់សូត្រ ដើម្បីបានជាពុទ្ធានុស្សតិរំលឹករឿយៗទៅដល់គុណរបស់ព្រះសម្មាសម្ពុទ្ធ ក៏ដូចជាគុណរបស់ព្រះធម៌ និងគុណរបស់ព្រះសង្ឃផងដែរ ។ ទោះបីសៀវភៅនេះ មិនមែនជាព្រះពុទ្ធដីកា របស់ព្រះអង្គទាំងស្រុងក៏ដោយ ប៉ុន្តែដោយយល់ឃើញថាអ្នកប្រាជ្ញខ្មែរយើង ជាអ្នកឆ្លៀវឆ្លាសក្នុងការតែងនិពន្ធជាពាក្យកាព្យ ពោលរៀបរាប់អំពីគុណរបស់ព្រះអង្គដែលអាចឱ្យយើងអ្នកអាន អ្នកស្តាប់ហើយរីករាយជ្រះថ្លានឹងការបំពេញបុណ្យ ទើបខ្ញុំព្រះករុណាអាត្មាភាពបានប្រមូលយកចងក្រងដាក់ក្នុងសៀវភៅនេះ ទុកសម្រាប់សូត្រក្នុង**អភិលក្ខិតកាល**ផ្សេងៗ ដូចជា **ថ្ងៃវិសាខបូជា មាឃបូជា អាសាឡ្ហបូជា** ជាដើម ។

ជាចុងក្រោយ ខ្ញុំព្រះករុណាក៏សូមខន្តីអធ្យាស្រ័យរាល់កំហុសឆ្គងទាំងអស់ដែលកើតមានឡើង ទោះបីដោយចេតនាក្ដី អចេតនាក្ដី សូមវិញ្ញូជនទាំងឡាយ មេត្តាជួយកែតម្រូវចំពោះកំហុសឆ្គងទាំងនោះដោយអនុគ្រោះផងចុះ ហើយខ្ញុំព្រះករុណាសូមលើកនូវមហាកុសលផលបុណ្យ ដោយអំណាចនៃការខិតខំប្រឹងប្រែងធ្វើសៀវភៅនេះ ប្រគេនចំពោះព្រះករុណាគុណម្ចាស់គ្រប់ៗអង្គ និងជូនចំពោះអ្នកដ៏មានគុណទាំងឡាយរបស់ខ្ញុំព្រះ-ករុណា មានមាតាបិតា គ្រូឧបជ្ឈាយាចារ្យ ព្រមទាំងឧទ្ទិសចំពោះពពួកញាតិទាំងអស់ ដែលបានចែកឋានទៅហើយនោះ ដើម្បីបានជាបច្ច័យរស់នៅជាសុខ និងបានជាឧបនិស្ស័យបានសម្រេចព្រះនិព្វានកុំបីក្លាយជាបការៈដ៏ទៃឡើយ ។

សូមអនុមោទនា !!!

វត្តស្លាកែត,ថ្ងៃអាសាឡ្ហបូជា ១៥កើត ខែ អាសាឍ ព.ស.២៥៥៨

ខ្ញុំព្រះករុណា អាត្មាភាព

*ភិក្ខុចន្ទប្បញ្ញោ អ៊ឹប ភារុណ*

# អ្នកមានឧបការៈគុណក្នុងការចេញធម្មទាន

- លោកគ្រូអគ្គប្បញ្ញោ កែវ និស្ស័យ ចៅអធិការវត្តស្លាកែត
- លោកគ្រូបិណ្ឌិតចារិតោ ពៅ មុនី គ្រូសូត្រឆ្វេងវត្តស្លាកែត
- ម្ចាស់គ្រូជោតិធម្មោ ភ្លន់ ភ្លី (ចៅអធិការវត្តព្រះពុទ្ធអណ្តែត)
- ម្ចាស់គ្រូសីលរក្ខិតោ ចិន ស៊ីឃាំង (គ្រូសូត្រឆ្វេងវត្តព្រះពុទ្ធអណ្តែត)
- ភិក្ខុធម្មសរោ ហាត សារៈ
- ភិក្ខុសិរីបាលោ មី ហាង
- សាមណេរធម្មសារោ អ៊ឹប សៅរិន
- សាមណេរសីលសារោ ហាត់ ដេត
- សាមណេរកល្យាណោ យ៉ត មាបុង
- សាមណេរភទ្ទបណ្ឌិតោ ឡឿន រិទ្ធី
- សាមណេរវរប្បញ្ញោ ស៊ត់ ស៊ីម
- សាមណេរសុមនី លីម សុខជា
- សាមណេរបញ្ញាបាលោ រឿន សីហា
- សាមណេរជោតិបាលោ យឿត ឆៃយ៉ា
- សាមណេរចន្ទរាមោ ខុម ចាន់រី
- យុវជន យឿន តាក់ និស្សិតសាកលវិទ្យាល័យបៀលប្រាយ
- វិញ្ញូសមណៈវត្តស្លាកែត

# មាតិកា

ឈ្មោះអត្ថបទ ទំព័រ

បទសារភញ្ញ.......................................................១
រតនត្តយបូជា .......................................................២
ពុទ្ធរតនប្បណាម .......................................................២
ពុទ្ធរតនប្បណាម .......................................................២
ពុទ្ធគុណ .......................................................៣
ពាក្យប្ដេជ្ញាចិត្តពាក្យខមាទោស.......................................................៤
ធម្មរតនប្បណាម .......................................................៥
ធម្មគុណ.......................................................៦
ពាក្យប្ដេជ្ញាចិត្ត និងខមាទោស.......................................................៧
សង្ឃរតនប្បណាម.......................................................៨
សង្ឃគុណ .......................................................៨
ពាក្យប្ដេជ្ញាចិត្ត និងខមាទោស.......................................................៩
នមស្ការបូជនីយវត្ថុ....................................................... ១០
នមស្ការព្រះរតនត្រ័យ ....................................................... ១០
នមស្ការពុទ្ធបាទ ....................................................... ១២
បត្តិទានគាថា ....................................................... ១៤

បត្តិទានគាថា ........................................ ១៥
បត្តនាគាថា ........................................ ១៦
បត្តិទានគាថា ........................................ ១៧
ធម៌ផ្សាយមេត្តា........................................ ១៨
ឯតទគ្គបុគ្គលបាលី........................................ ២១
បទលើកទង់ព្រះពុទ្ធសាសនា........................................ ២៦
បទសូត្រដាក់ទង់ព្រះពុទ្ធសាសនា ........................................ ២៧
ពង្សាវតារខ្មែរ........................................ ២៩
បទនគររាជ........................................ ៣០
មាឃបុណ្ណមី ........................................ ៣១
វិសាខបុណ្ណមី ........................................ ៣២
វិសាខបុណ្ណមី ........................................ ៣៣
អាសាឡ្ហបូជា ........................................ ៣៤
គោតមប្រវត្តិថ្មី ........................................ ៣៦
គោតមប្រវត្តិ(បុរាណ)........................................ ៣៩
ខ្ញុំនឹកព្រះណាស់........................................ ៤០
ព្រះអង្គទ្រង់ប្រសូត........................................ ៤១
ព្រះអង្គទ្រង់ត្រាស់ដឹង ........................................ ៤២
ព្រះពុទ្ធដាក់អាយុសង្ខារ-បរិនិព្វាន ........................................ ៤៤

បារមី ៣០.................................................................. ៤៦
ពុទ្ធជយមង្គល ........................................................ ៤៩
ពុទ្ធោ នាគល់ព្រះពោធិព្រឹក្ស ........................................ ៥៥
ធម្មនិយាម ៣០............................................................ ៥៨
របស់ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ ................................ ៥៨
ឧបមាគុណព្រះរតនត្រៃ ២២ ប្រការ.................................. ៦២
ពុទ្ធកិច្ច ៥ យ៉ាង ........................................................ ៧០
រក្សាព្រះត្រៃបិដក ....................................................... ៧២
ការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ...................................... ៧៣
បណាមគាថា ............................................................. ៧៤
សុខាភិយាចនគាថា........................................................ ៧៥
សេចក្តីត្រិះរិះរបស់នាងវិសាខា ........................................ ៧៧
គុណរបស់ទាន............................................................. ៧៧
នមស្ការព្រះរតនត្រៃ...................................................... ៧៨
រាយនាមអ្នកមានសទ្ធាចូលរួមធម្មទាន .............................. ៧៩

# បទសារភញ្ញ

១.សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្តា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។
ចង្អុលឲ្យដើរផ្លូវកណ្ដាល មាគ៌ាត្រកាលអាចកំចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយបាត់ អាចកាត់សង្សារទុក្ខបាន ។
២.សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបុរាណ
ប្រឹងរៀនប្រឹងស្ដាប់ចេះចាំបាន កាន់តាមលំអានបានក្ដីសុខ ។
ឥតមានសុខណាស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្ដីសុខនឹងមានព្រោះធម៌ស្ងប់ ។
៣.ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្នគួរគោរព ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្ដា
សូមគុណត្រៃរ័ត្នជួយខេមរា ឲ្យបានសុខាតរៀងទៅ ៕

*ព្រះរាជនិពន្ធដោយសម្ដេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន ណាត***

# រតនត្តយបូជា

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និងធូបជាដើមនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

# ពុទ្ធរតនប្បណាម

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ ៣ ចប់ ។

វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

# ពុទ្ធរតនប្បណាម

យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ មហតឹ វិជេយ្យោ សម្ពោ-ធិមាគច្ឆិ អនន្តញ្ញាណោ លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។

ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបាន-

ស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរបានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវ សម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាង សត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធ អង្គនោះដោយគោរព ។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**
**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។**

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្ដី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្ដី ព្រះសម្មាសម្ពុទ្ធទាំង-ឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្ទកប្បនេះក្ដី ខ្ញុំព្រះ-ករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

# ពុទ្ធគុណ

**ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺ កិលេសព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះ-

អង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមាន ដំណើរល្អយាង ទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាម ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណា មួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះ ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមាន ឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គ ជាសាស្តាចារ្យនៃទេវតា និងមនុស្ស ទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវ ចតុរារិយសច្ចហើយញ៉ាំងអ្នកដទៃឲ្យ ត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាម ថា ភគវា ព្រោះព្រះអង្គមានដំណើរ ទៅកាន់ត្រៃភពខ្ទាក់ចោលហើយ គឺថា ព្រះអង្គមិនត្រឡប់កើតទៀត ឡើយ ។

# ពាក្យប្ដេជ្ញាចិត្តពាក្យខមាទោស

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយម-ង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយា ពោលនូវពាក្យសច្ចៈនេះ ។**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះ-

ករុណាសូមថ្វាយ បង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយ អវយវៈដ៏ឧត្តម គឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

# ធម្មរតនប្បណាម

**អដ្ឋង្គិការិយបថោ ជនានំ មោក្ខប្បវេសាយ ឧជូ ច មគ្គោ ធម្មោ អយំ សន្តិករោ បណីតោ និយ្យានិកោ តំ បនមាមិ ធម្មំ ។**

ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឲ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណ ញ៉ាំងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសទ្ធម្មនោះ ដោយគោរព ។

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**
**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធដែលនិព្វានកន្លងទៅហើយក្ដី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្ដី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាល

សព្វថ្ងៃនេះក្ដី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

# ធម្មគុណ

**ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងហើយដោយល្អ (**ធម្មោ** ព្រះនព្វ-លោកុត្តរធម៌មាន ៩ ប្រការគឺ មគ្គ ៤ ផល ៤ និព្វាន ១ ) **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខណ-ញ្ញាណ គឺថា នឹងបានដឹងដោយស្ដាប់ ដោយជឿបុគ្គលដទៃ នោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផល មិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថា បើព្រះអរិយបុគ្គលដែលបានសម្រេច មគ្គផលហើយក៏គួរនឹងហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញ ទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន ។

# ពាក្យប្ដេជ្ញាចិត្ត និងខមាទោស

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយម-ង្គលំ**

សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោល នូវពាក្យសច្ចៈនេះ **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមាន ២ ប្រការគឺ ព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ដោយអវយវៈដ៏ឧត្តមគឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

# សង្ឃរតនប្បណាម

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ សព្វមលប្បហីនោ គុណេហិនេកេហិ សមិទ្ធិបត្តោ អនាសវោ តំ បនមាមិ សង្ឃំ ។**

ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**
**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណាដែលជាព្រះសង្ឃ

នឹងបានសម្រេចមគ្គ និងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំង ឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលក្នុង កាលជាបច្ចុប្បន្ន នេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃ ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

# សង្ឃគុណ

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃ ព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះ-សង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺ ប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរស ទាំងឡាយមាន ៤គូ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផល ជាគូ១ សកទាគាមិមគ្គ និងសកទាគាមិផល ជាគូ១ អនាគាមិមគ្គ និងអនាគាមិផល ជាគូ១ អរហត្តមគ្គ និងអរហត្តផល ជាគូ១ **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃ ដែលបានសម្រេចនូវសោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិ-មគ្គ១

សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវ អាគន្តុកទាន គឺទាន ដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយ បូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោក គប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែង ជាងគ្មាន ។

# ពាក្យប្តេជ្ញាចិត្ត និងខមាទោស

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយ-មង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយ កិរិយាពោលនូវពាក្យសច្ចៈនេះ ។

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះកុរណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការគឺ សម្មតិសង្ឃ និងអរិយ-សង្ឃដោយអវយវៈដ៏ឧត្តមគឺត្បូង **សង្ឃេ យោ ខលិតោ ទោសោ**

ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃ ជាម្ចាស់ **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោស នោះដល់ខ្ញុំព្រះករុណា ។

# នមស្ការបូជនីយវត្ថុ

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតដ្ឋិតំ**
**សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ។**

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកម្បង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ឋាននានានោះទាំងអស់។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្រ។
សូមទាន់ព្រះអរិ- យមេត្រីថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ៕

# នមស្ការព្រះរតនត្រ័យ

**យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ អតិទុក្ករានិ ខេទំ គតោ**

**លោកហិតាយ នាថោ នមោ មហាការុណិកស្ស តស្ស ។**

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាង អស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ សត្តនិករគ្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ ជីវលោកោ នមោ អវិជ្ជានិក្កិលេសជាលំ វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល
ឲ្យវិលវល់អន្ទោល ក្នុងភពតូច និងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
ព្រះពុទ្ធតែងសេពសម ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់អវិជ្ជា គឺបណ្ដាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញាវិមុត្តិញ្ញាណប្បភុតីហិ យុត្តោ ខេត្តញ្ញាណំ កុសលត្ថិកានំ តមរិយសង្ឃំ សិរសា នមាមិ ។**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់

កបដោយគុណសីលត្រង់ និងសមាធិបញ្ញា
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

**ឥច្ចេវមច្ចន្តនមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ ។**

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា។
សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឲ្យកម្ចាត់បង់ អពមង្គលទាំងឡាយ
ឲ្យជៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

# នមស្ការពុទ្ធបាទ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ។**

ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញុំាងជនជាអនន្តឲ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំង នៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយជាទីពឹងនៃ សព្វសត្វក្នុងត្រៃភព ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនា ច លគ្គេ យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ តំ បាទលញ្ឆនមហំ សិរសា នមាមិ ។**

ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្នូរខ្សាច់ ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទ ឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូម ក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំង អស់នោះ នៃព្រះសក្យមុនី ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ នទិយា បញ្ច បាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែងគឺ ស្ថានលើភ្នំសុវណ្ណមាលិក១ លើភ្នំសុវណ្ណបព៌ត១ លើភ្នំសុមនកូដ១ ក្នុងយោនកបុរី១ ក្បែរស្ទឹងនម្មទា១ ។

# បត្តិទានគាថា

(សូត្រសម្រាប់ចែកចំណែកបុណ្យ)

**យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងទីវត្ត ជាទីនៅនៃសង្ឃ ឰដ៏ខឿនព្រះសថូប ឰដ៏ខឿនព្រះពោធិព្រឹក្សក្នុងទីនោះៗ **តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយបូជាហើយដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្ដីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយជាថេរៈក្ដី ជាកណ្ដាលក្ដី ទើបនឹងបួសថ្មីក្ដី **សារាមិកា ទានបតី ឧបាសកា** ឧបាសក និងឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញោមវត្តក្ដី **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែលជាអ្នកស្រុកក្ដី ជាអ្នកប្រទេសក្ដី ជាអ្នកនិគមក្ដី ដែលជាឥស្សរៈជាធំក្ដី **សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះ ចូរឲ្យបាននូវសេចក្ដីសុខ **ជលាពុជា យេបិ ច អណ្ឌ-សម្ភវា សំសេទជាតា អថវោបបាតិកា** មួយវិញទៀត សត្វទាំងឡាយឯណាដែលជាជលាពុជៈកំណើតក្ដី ដែលជាអណ្ឌជៈ កំណើតក្ដី ដែលជាសំសេទជៈកំណើតក្ដី ដែលជាឱបបាតិកៈកំណើតក្ដី **និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** សូមឲ្យធម៌របស់

សប្បុរសទាំងឡាយស្ថិតនៅអស់កាល យូរអង្វែងទៅ **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ចូរស្ថិតនៅអស់កាលយូរអង្វែងទៅ **សង្ឃោ ហោតុ សមគ្គោ វ** សូម ព្រះសង្ឃព្រមព្រៀងគ្នា **អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្ដីចម្រើនផង ដើម្បីសេចក្ដីសម្រេចផលប្រយោជន៍ផង **អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នក ដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង **វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ** សូមឲ្យយើងទាំងឡាយបានដល់នូវសេចក្ដីចម្រើន ក្នុងធម៌ដែលព្រះអរិយៈទាំង- ឡាយលោកសម្ដែងហើយ ។

# បត្តិទានគាថា

(សូត្រសម្រាប់ចែកចំណែកបុណ្យ)

**ឥមិនា បុញ្ញកម្មេន** ដោយបុញ្ញកម្មនេះ **ឧបជ្ឈាយា គុណុត្តរា** ឧបជ្ឈាយ៍ទាំងឡាយមានគុណដ៏ខ្ពង់ខ្ពស់ក្ដី **អាចរិយូបការា ច** អាចារ្យទាំងឡាយ មានឧបការៈក្ដី **មាតាបិតា បិយា មមំ** មាតាបិតាជាទីស្រឡាញ់នៃខ្ញុំក្ដី **សុរិយោ ចន្ទិមា រាជា** ព្រះអាទិត្យ ព្រះចន្ទ និង ព្រះ-រាជាក្ដី **គុណវន្តា នរាបិ ច** មួយវិញទៀត ជនទាំងឡាយដែលជា អ្នកមានគុណក្ដី **ព្រហ្មា មារា ច ឥន្ទ្រា ច** ពួកព្រហ្មក្ដី មារក្ដី ព្រះឥន្ទ្រទាំងឡាយក្ដី **លោកបាលា ច ទេវតា** ទេវតាទាំងឡាយជាអ្នករក្សានូវលោកក្ដី **យមោ មិត្តា មនុស្សា ច** យមរាជក្ដី ពួកមនុស្សជាទីរាប់អាន គ្នាក្ដី **មជ្ឈត្តា វេរិកាបិ ច** មួយវិញទៀត សត្វទាំងឡាយដែលមានចិត្ត ជា

ឧបេក្ខាក្តី មានពៀរនឹងគ្នាក្តី **សព្វេ សត្តា សុខី ហោន្តុ** សព្វសត្វទាំងឡាយ ចូរឲ្យបាននូវសេចក្តីសុខ **បុញ្ញានិ បកតានិ មេ** បុណ្យទាំងឡាយដែលខ្ញុំបានធ្វើហើយ **សុខញ្ច តិវិធំ ទេន្តុ** សូមឲ្យបាននូវសេចក្តីសុខទាំង ៣ ប្រការ (គឺសុខក្នុងមនុស្ស ទេវតា និងព្រះនិព្វាន) **ខិប្បំ បាបេថ វោមតំ** អ្នកទាំងឡាយចូរដល់នូវព្រះនិព្វាន ឈ្មោះអមតៈដោយឆាប់រួសរាន់ទាន់ចិត្ត ។

# បត្ថនាគាថា

(សូត្រសម្រាប់តាំងសេចក្តីប្រាថ្នា)

**ឥមិនា បុញ្ញកម្មេន** ដោយបុញ្ញកម្មនេះផង **ឥមិនា ឧទ្ទិសេន ច** ដោយពាក្យឧទ្ទិសនេះផង **ខិប្បាហំ សុលភេ ចេវ តណ្ហុប្បាទានឆេទនំ** ខ្ញុំគប្បីបានដោយងាយនូវការផ្តាច់តណ្ហានិងឧបាទានដោយឆាប់រួស- រាន់ **យេ សន្តានេ ហីនា ធម្មា** ធម៌ទាំងឡាយណាដែលថោកទាប មានក្នុងសន្តាន (នៃខ្ញុំ) **យាវ និព្វានតោ មមំ នស្សន្តុ សព្វទាយេវ** ធម៌ថោកទាបទាំងនោះ ចូរវិនាសទៅ (ចាកសន្តាន) នៃខ្ញុំសព្វកាល ដរាបដល់ព្រះនិព្វាន **យត្ថ ជាតោ ភវាភវេ** ខ្ញុំកើតហើយក្នុងភពតូច និងភពធំណាៗ **ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ វិរិយោម្ហិ វា** សូមឲ្យជាអ្នកមានចិត្តត្រង់ ដោយស្មារតី និងប្រាជ្ញា ទាំងសូមឲ្យមាន ចិត្តផូរផង់ និងសេចក្តីព្យាយាមផង(ក្នុងភពនោះៗ) **មារា លភន្តុ នោកាសំ កាតុញ្ច វិរិយេសុ មេ** មារទាំងឡាយចូរកុំបាននូវឱកាសដើម្បី ធ្វើ(នូវសេចក្តី អន្តរាយ) ក្នុងព្យាយាមទាំងឡាយនៃខ្ញុំ **ពុទ្ធោ ទីបវរោ នាថោ** ព្រះពុទ្ធដូចជាប្រទីប

ដ៏ប្រសើរ ព្រះអង្គជាទីពឹង(របស់ខ្ញុំ) **ធម្មោ នាថោ វរុត្តមោ** ព្រះធម៌ដ៏ឧត្ដម បវរជាទីពឹង (របស់ខ្ញុំ) **នាថោ បច្ចេកពុទ្ធោ ច** ព្រះ-បច្ចេកពុទ្ធក៏ជាទីពឹង (របស់ខ្ញុំ) **សង្ឃោ នាថោត្តរោ មមំ** ព្រះសង្ឃជាទីពឹងដ៏ប្រសើររបស់ខ្ញុំ **តេសោត្តមានុភាវេន** ដោយឧត្តមានុភាពនៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃទាំងឡាយនោះ **មារោកាសំ លភន្តុ មា** មារចូរកុំបាន នូវឱកាសឡើយ ។

# បត្តិទានគាថា

(សូត្រសម្រាប់ចែកចំណែកបុណ្យ)

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ **កាយេន វាចាមនសា** ដោយទ្វារទាំងបី គឺកាយ វាចា ចិត្ត **តិទសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយជាកុសលអាចនឹងនាំទៅកើតក្នុងស្ថានត្រៃត្រិង្សសួគ៌បាន **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្មដែល ជាសត្វមានសញ្ញាក្ដី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយ ឯណាជាអសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្ដី **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះឲ្យបានសោយនូវផលនៃបុណ្យ

ដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ **យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹងដល់សត្វទាំងឡាយនោះ ឲ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនា ត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយទៅឲ្យនេះចុះ ។

# ធម៌ផ្សាយមេត្តា

**សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសបូព៌ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសអគ្នេយ៍ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសទក្សិណ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសនិរតី សូមកុំឲ្យមាន ពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសខាងលិច សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសពាយ័ព្យ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសខាងជើង សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសឦសាន សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសខាងក្រោម សូមកុំឲ្យ

មានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងទិសខាងលើ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ សត្តា អវេរា ហោន្តុ** សូមឲ្យសត្វទាំងឡាយទាំងពួង កុំមានពៀរនឹងគ្នា **សុខិតា ហោន្តុ** សូមឲ្យបាននូវសេចក្តីសុខ **និទ្ទុក្ខា ហោន្តុ** សូមកុំឲ្យមានទុក្ខ **អព្យាបជ្ឈា ហោន្តុ** សូមកុំឲ្យបៀតបៀន ដល់គ្នានឹងគ្នា **អនីឃា ហោន្តុ** សូមកុំឲ្យមានសេចក្តីព្រួយលំបាក **ទីឃាយុកា ហោន្តុ** សូមឲ្យមានអាយុវែង **អរោគា ហោន្តុ** សូមកុំឲ្យមានរោគ **សម្បត្តីហិ សមិជ្ឈន្តុ** សូមឲ្យបានសម្រេចដោយ សម្បត្តិគ្រប់យ៉ាង **សុខី អត្តានំ បរិហរន្តុ** សូមឲ្យរក្សាខ្លួននៅ ជាសុខស្រួលចុះ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**
**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

មួយទៀត សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជា សត្វបាត់ភ័យទៅ ដែលដល់ហើនូវសេចក្តីសោក សូមឲ្យជាសត្វ បាត់សេចក្តីសោកទៅ ។

# ឯតទគ្គបុគ្គលបាលី

**(បិដកលេខ ៤០,ទំព័រ ៥៣-៥៤)**

**❖ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ:**

**១-រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ ។**

**២-មហាបញ្ញានំ យទិទំ សារីបុត្តោ ។**

**៣-ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ ។**

**៤-ធុតវាទានំ យទិទំ មហាកស្សបោ ។**

**៥-ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ ។**

**៦-ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ កាឡិគោធាយបុត្តោ ។**

**៧-មញ្ជុស្សរានំ យទិទំ លកុណ្ឌកភទ្ទិយោ ។**

**៨-សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោ ។**

**៩-ធម្មកថិកានំ យទិទំ បុណ្ណោ មន្តានីបុត្តោ ។**

**១០-សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោតិ ។**

**វគ្គោ បឋមោ ។**

**❖ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ**

**១-មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្លបន្ថកោ ។**

**-ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ ។**

**២-បញ្ញាវិវដ្ដកុសលានំ យទិទំ មហាបន្ថកោ**

**៣-អរណាវិហារីនំ យទិទំ សុភូតិ ។**

**-ទក្ខិណេយ្យានំ យទិទំ សុភូតិ ។**

**៤-អារញ្ញកានំ យទិទំ រេវតោខទិរវនិយោ ។**

**៥-ឈាយីនំ យទិទំ កង្ខារេវតោ ។**

**៦-អារទ្ធវីរិយានំ យទិទំ សោណោ កោលិវិសោ ។**

**៧-កល្យាណវាក្ករណានំ យទិទំ សោណោ កុដិកណ្ណោ ។**

**៨-លាភីនំ យទិទំ សីវលី ។**

**៩-សទ្ធាធិមុត្តានំ យទិទំ វក្កលីតិ ។**

**វគ្គោ ទុតិយោ ។**

**❖ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ:**

**១-សិក្ខាកាមានំ យទិទំ រាហុលោ ។**

**២-សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ។**

**៣-បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ ។**

**៤-បដិភាណវន្តានំ យទិទំ វង្គីសោ ។**

**៥-សមន្តប្បសាទិកានំ យទិទំ ឧបសេនោ វង្គន្តបុត្តោ ។**

**៦-សេនាសនប្បញ្ញាបកានំ យទិទំ ទព្វោ មល្លបុត្តោ ។**

**៧-ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ ។**

**៨-ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ ។**

**៩-ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។**

**១០-បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោតិ ។**

**វគ្គោ តតិយោ ។**

### ❖ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ

១-ពហុស្សុតានំ យទិទំ អានន្ទោ ។

★-សតិមន្តានំ យទិទំ អានន្ទោ

★-គតិមន្តានំ យទិទំ អានន្ទោ

★-ធិតិមន្តានំ យទិទំ អានន្ទោ

★-ឧបដ្ឋាកានំ យទិទំ អានន្ទោ។

២-មហាបរិសានំ យទិទំ ឧរុវេលកស្សបោ ។

៣-កុលប្បសាទកានំ យទិទំ កាឡុទាយិ ។

៤-អប្បាពាធានំ យទិទំ ពក្កុលោ ។

៥-បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ។

៦-វិនយធរានំ យទិទំ ឧបាលិ ។

៧-ភិក្ខុនោវាទកានំ យទិទំ នន្ទកោ ។

៨-ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ ។

៩-ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ ។

១០-តេជោធាតុកុសលានំ យទិទំ សាគតោ ។

១១-បដិភាណេយ្យកានំ យទិទំ រាធោ ។

១២-លូខចីវរធរានំ យទិទំ មោឃរាជាតិ ។

វគ្គោ ចតុត្ថោ ។

### ❖ ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ:

១-រត្តញ្ញូនំ យទិទំ មហាបជាបតី គោតមី ។

២-មហាបញ្ញានំ យទិទំ ខេមា ។

៣-ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា ។

**៤-វិនយធរានំ យទិទំ ឧបាលិ ។**

**៥-ធម្មកថិកានំ យទិទំ ធម្មទិន្នា ។**

**៦-ឈាយិនីនំ យទិទំ នន្ទា ។**

**៧-អារទ្ធវិរិយានំ យទិទំ សោណា ។**

**៨-ទិព្វចក្ខុកានំ យទិទំ សកុលា ។**

**៩-ខិប្បាភិញ្ញានំ យទិទំ ភទ្ទា កុណ្ឌលកេសា ។**

**១០-បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទា កបិលានី ។**

**១១-មហាភិញ្ញាបត្តានំ យទិទំ ភទ្ទា កច្ចានា ។**

**១២-លូខចីវរធរានំ យទិទំ កិសាគោតមី ។**

**១៣-សទ្ធាធិមុត្តានំ យទិទំ សិគាលមាតាតិ ។**

**វគ្គោ បញ្ចមោ ។**

**❖ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ:**

**១-បឋមំ សរណំ គច្ឆន្តានំ យទិទំ តបុស្សភល្លិកា វាណិជា ។**

**២-ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ ។**

**៣-ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិកសណ្ឌិកោ ។**

**៤-ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ ហត្ថកោ អាឡវកោ ។**

**៥-បណីតទាយិកានំ យទិទំ មហានាមោ សក្កោ ។**

**៦-មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ ។**

**៧-សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ ។**

៨-អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ ។
៩-បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ ។
១០-វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ ។

វគ្គោ ឆដ្ឋោ ។

❖ ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ:

១-បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា ។
២-ទាយិកានំ យទិទំ វិសាខា មិគារមាតា ។
៣-ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា ។
៤-មេត្តាវិហារីនំ យទិទំ សាមាវតី ។
៥-ឈាយិនីនំ យទិទំ ឧត្តរា នន្ទមាតា ។
៦-បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា ។
៧-គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា ។
៨-អវេច្ចប្បសន្នានំ យទិទំ កាតិយានី ។
៩-វិស្សាសិកានំ យទិទំ នកុលមាតា គហបតានី ។
១០-អនុស្សវប្បសន្នានំ យទិទំ កាលី ឧបាសិកា កុររឃរិកាតិ ។

វគ្គោ សត្តមោ ។

# បទលើកតម្កើងព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី
ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស
ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក ។
ប្រទេសតូចធំ បានស្ម័គ្រស្មាគម
ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក
ប្រសើរពន់ពេកក្រៃកន្លង ។
ធ្វើជាសញ្ញា ទង់ជ័យសាសនា
នៃព្រះសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង
នឹកដល់ព្រះអង្គជាអម្ចាស់ ។
ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា
សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់
ប្រឹងប្រែងឲ្យណាស់គ្រប់ៗគ្នា ។
សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត
រុងរឿងវិសុទ្ធថ្លៃថ្លា

ហើយមានជ័យជោគ ផ្សាយពេញលោកា
ដោយជនជ្រះថ្លាច្រើនសែនលាន ។
មានចិត្តស្នេហា គោរពបូជា
ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ
ប្រាថ្នាចង់បានសេចក្តីសុខ ។
យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត
កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ
ទើបនឹងបានសុខក្សេមក្សាន្តត្រាណ។
ព្រមព្រៀងប្រព្រឹត្ត តាមធម៌សុចរិត
ឆ្ពោះទៅកាន់ឋាននិព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត
ជាតិយើងនឹងបានសោយសុខា ៕

*និពន្ធដោយសម្តេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន.ណាត***

## បទស្បូត្រដាក់ទង់ព្រះពុទ្ធសាសនា

ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។

ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិវង្គប្រសើរបវរ
ផ្ទៀលឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា កាលដែលនៅជាព្រះពោធិសត្វ ។
**១.រស្មីពណ៌ខៀវនោះណា** កាលឆ្កៀលនេត្រាទ្រង់ដោយចិត្តកាត់
ឱ្យទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីពិរាស្រ្ត ។
**២.រស្មីពណ៌លឿងភ្លឺថ្លា** កាលដែលទ្រង់អារសាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទ្រជាងមាសទ្រង់វៃបណ្ឌិត ។
**៣.រស្មីក្រហមនោះណា** កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស៊ូប្ដូរជីវិត កាត់បេះដូងបិទធ្វើថ្នាំមាតា។
**៤.រស្មីពណ៌សសុទ្ធសាធ** កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឱ្យទានដំរីសសោភា ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញាណ។
**៥.រស្មីពណ៌ដូចជើងហង្ស** កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ ឲ្យយក្សសាមាន្យស៊ីប្ដូរជីវិត។
**៦.រស្មីពណ៌ផ្លេកពណ្ណរាយ** កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឲ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។
រស្មីខៀវលឿងក្រហម សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារចងចាំទុកអើយ ។

*និពន្ធដោយសម្ដេចព្រះសង្ឃរាជ* ***ជោតញ្ញាណោ ជួន.ណាត***

# ពង្សាវតារខ្មែរ

❖ ខ្មែរអើយចូរចាំជាក់ថា តាមពង្សាវតារ
បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង
ទឹកដីខ្មែរធំ ទូលំទូលាយ
សព្វសាយរុងរឿង គេឯងតែងលើកតម្កើង
តម្កល់ជាតិយើង ចាត់ទុកឡើងជាជាតិច្បង ។

❖ អារ្យធម៌ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយ
គ្រប់ទិសទាំងឡាយ ចុងបូព៌ា
សាសនាសិល្បៈ ចម្លាក់វិចិត្រ
គំនិតសិក្សា តន្ត្រីទស្សនវិជ្ជា
អាចយកសិក្សា ជាគោលការណ៍ខ្មែរផ្សាយទៅ ។

❖ ខ្មែរអើយចូរស្ដាប់សាវតា ដែលបានចរចារ
បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង
តាំងចិត្តឱ្យធំ ខិតខំប្រឹងវេញ
បញ្ចេញតម្កើង តម្លៃនៃជាតិខ្មែរយើង
ឱ្យបានរុងរឿង ជាថ្មីឡើងតាមសាវតារ។

*ព្រះរាជនិពន្ធដោយ សម្ដេចព្រះសង្ឃរាជជួន ណាត*

# បទនគររាជ

❖ សូមពួកទេព្តា រក្សាមហាក្សត្រយើង
ឱ្យបានរុងរឿង ដោយជ័យមង្គលសិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន។

❖ ប្រាសាទសិលា កំបាំងកណ្ដាលព្រៃ
គួរឱ្យស្រមៃ នឹកដល់យសស័ក្តិមហានគរ
ជាតិខ្មែរដូចថ្ម គង់វង្សនៅល្អរឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ។

❖ គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រតាមបែបដូនតា
គង់តែទេព្តា នឹងជួយជ្រោមជ្រែង ផ្គត់ផ្គង់ប្រយោជន៍ឱ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ។

*និពន្ធឡើងដោយសម្ដេចសង្ឃរាជ **ជួន ណាត** នៅថ្ងៃទី ២០ កក្កដា ១៩៤១*

# មាឃបុណ្ណមី

❖ **មាឃបុណ្ណមី** ថ្ងៃនក្ខត្តឫក្ស ធ្វើបុណ្យរំលឹកហេតុពីរប្រការ
ដែលព្រះសម្ពុទ្ធវិសុទ្ធថ្លៃថ្លា មានករុណាសង្គ្រោះសត្វលោក ។
❖ **មាឃបុណ្ណមី** ប្រជុំសាវ័ក សន្និបាតជាក់ នៃព្រះមានជោគ
ប្រកបដោយអង្គសង្ឃច្រើនគគោក ឆ្លងផុតចាកលោកមិនមានអាល័យ ។
❖ **មាឃបុណ្ណមី** ថ្ងៃព្រះសាស្ដា ទ្រង់ត្រាស់វាចាមិនមានទុក្ខភ័យ
ដាក់នូវអាយុសង្ខារនោះនៃ កញ្ច្រែកផែនដី មួយម៉ឺនចក្រវាឡ ។
❖ **មាឃបុណ្ណមី** មានហេតុប្លែកៗ អស្ចារ្យចម្លែកមានក្នុងសាសនា
ជាប់ដោយព្រះគុណនៃព្រះសម្មា-សម្ពុទ្ធនោះណាករុណាក្រៃលែង ។
❖ **មាឃបុណ្ណមី** មានចិត្តសទ្ធា ជ្រះថ្លាគ្រប់គ្នាគោរពកោតក្រែង
បូជាព្រះអង្គ និងសង្ឃគម្ដែង មានចិត្តស្ងប់ស្ងែងបូជាដល់គុណ ។
❖ **មាឃបុណ្ណមី** ក្រុមពួកសង្ឃជី បរិស័ទមូលមីរប្រសើរពេកពន់
ប្រព្រឹត្តបូជាឱនកាយបន្ទន់ ទឹកចិត្តទន់ភ្លន់ ដ៏ល្អប្រពៃ ។
❖ **មាឃបុណ្ណមី** ចម្រើនកុសល លះកាត់កង្វល់ ខំប្រឹងលកលៃ
ធ្វើពេលវេលាឱ្យមានតម្លៃ ពីព្រឹកដល់ថ្ងៃ ដោយមិនប្រមាទ ។
❖ **មាឃបុណ្ណមី** មានន័យខ្លាំងណាស់ ព្រះអង្គទ្រង់ត្រាស់នូវព្រះឱវាទ
ប្រាប់បេះដូងធម៌ក្នុងសន្និបាត បរិសុទ្ធស្អាតវិសេសវិសិដ្ឋ ។
❖ **អាសាឍ វិសាខ មាឃបុណ្ណមី** សាវ័កប្រុសស្រី ប្រឹងទូន្មានចិត្ត
ឱ្យបានថ្លាស្អាត ផុតចាកទុច្ចរិត មិនមានវិបរិត នឹងបានសុខស្ងប់ ៕

*ដោយភិក្ខុ សុវណ្ណជោតោ ត.ស.រ.*

# វិសាខបុណ្ណមី

▪**វិសាខបុណ្ណមី** គួរឱ្យជ្រះថ្លា ថ្ងៃព្រះសាស្តាសម្មាសម្ពុទ្ធ
ប្រសូតចាកគភ៌ ស្អាតបរិសុទ្ធ វិសេសបំផុតនៅក្នុងលោកា។
▪**វិសាខបុណ្ណមី** ថ្ងៃទ្រង់ត្រាស់ដឹង ដែលទ្រង់រំពឹងបច្ចយាការ
បច្ចុសសម័យព្រះទ័យស្រស់ថ្លា ត្រាស់ជាសម្មាសម្ពុទ្ធក្នុងលោក។
▪**វិសាខបុណ្ណមី** ថ្ងៃទ្រង់និព្វាន សត្វសែនកោដិលានមកច្រើនគគោក
ក្រាស់ក្រៃលត្រៀបត្រាភក្ត្រទទឹកជោក នាំគ្នាសោយសោកស្តាយព្រះសាស្តា។
▪**វិសាខបុណ្ណមី** ថ្ងៃព្រះទ្រង់ត្រាស់ បញ្ជាក់យ៉ាងច្បាស់ បច្ឆិមវាចា
ថាកុំប្រមាទ រៀលរាល់រូបា ចម្រើនបញ្ញា តាមព្រះមុនី ។
▪**វិសាខបុណ្ណមី** មានន័យខ្លាំងណាស់ បរិស័ទក្មេងចាស់គួរខំសម្តី
ស្រូតរូតស្រុះស្រួលស្តាប់ព្រះធម្មី ក្រុមពួកសង្ឃជីបានពោលសម្តែង
▪**វិសាខបុណ្ណមី** កម្ចាត់ងងឹត ដែលមានក្នុងចិត្តឱ្យភ្លឺចិញ្ចែង
លោភៈទោសៈមោហៈស្តែងៗ ពន្លឺសូរសែងប្រទីបបញ្ញា ។
▪**វិសាខបុណ្ណមី** ឋិតក្នុងសីលទាន ឱ្យបានជាយានឆ្លងកាត់សង្សារ
កាត់អបាយភូមិ ទុក្ខច្រើនក្រៃណា ចម្រើនមេត្តាដល់សត្វទាំងឡាយ។
▪**វិសាខបុណ្ណមី** អប់រំវិជ្ជា យល់ដឹងគ្រប់គ្នា មានចិត្តនឿយណាយ
ប្រាជ្ញាយល់ត្រូវ ងងឹតខ្ចាត់ខ្ចាយ ផុតអន្តរាយកាយចិត្តស្រស់ថ្លា។
▪ព្រះអង្គប្រសូត និងបានត្រាស់ដឹង និព្វានថ្ងៃហ្នឹងគួរពិចារណា
សង្ខារទាំងឡាយមិនទៀងទ្បើយណា គ្រប់រូបអាត្មាកើតចាស់ឈឺស្លាប់ ។
▪ចូរកុំប្រមាទនៅក្នុងទានសីល ដើម្បីផ្តាច់ផ្តិលរូតរះប្រញាប់
សម្មាទិដ្ឋិ ដែលទ្រង់បានប្រាប់ ឆ្ការគាស់កាយកាប់កិលេសតណ្ហា៕

# វិសាខបុណ្ណមី

វិសាខបុណ្ណមីគឺថ្ងៃវិសេស យើងបានចាំចេះថ្ងៃព្រះភគវា
ប្រាំពីរប្រការជ្រះថ្លាវន្ទា វិសាខបូជាឫក្សពារសែនល្អ ។
⭑**ទីមួយ** គឺថ្ងៃសុមេធបណ្ឌិត ពោធិសត្វពិតមានឫទ្ធិបវរ
ចាប់ផ្ដើមទទួលព្រះពុទ្ធព្យាករណ៍ លោកធាតុញាប់ញ័រសាទរពេកក្រៃ។
⭑**ទីពីរ** គឺថ្ងៃក្សត្រថ្លៃប្រសូត អស្ចារ្យរហូតសម្ពោធព្រឹក្សព្រៃ
កំណើតចុងក្រោយជាប់ដោយអត្ថន័យ ផុតចាកភពត្រៃលែងភ័យលែងព្រួយ។
⭑**ទីបី** គឺថ្ងៃព្រះស្រីមហាពោធិ៍ ដុះចេញលេចធ្លោពោធិ៍ពិតមានត្រួយ
ថ្ងៃព្រះប្រសូតស្រួតដុះជាមួយ ជំនួយឱ្យចិត្តបរិស័ទជ្រះថ្លា ។
⭑**ទីបួន** គឺថ្ងៃចមត្រៃត្រាស់ដឹង ថ្ងៃមានទីពឹងពំនឹងលោកា
ជាថ្ងៃព្រះពុទ្ធបរិសុទ្ធអស្ចារ្យ ពួកជនជ្រះថ្លាចិន្ដាល្អស្អាត ។
⭑**ទីប្រាំ** គឺថ្ងៃអង្គថ្លៃនិព្វាន ថ្ងៃព្រះទ្រង់ញាណមានពុទ្ធោវាទ
មច្ឆិមវាចាថាកុំប្រមាទ ឱវាទពិសិដ្ឋឋិតនៅជាគ្រូ ។
⭑**ប្រាំមួយ** គឺថ្ងៃប្រល័យព្រះធាតុ ចេតិយលោកនាថនៅទៀតមិនយូរ
ព្រះធាតុទាំងអស់ហោះមកគល់ពោធិ៍ តេជោរំលាយរំលត់ពុទ្ធសាសន៍។
⭑**ប្រាំពីរ** គឺថ្ងៃជោគជ័យពុទ្ធា គ្រប់ព្រះភគវាឈ្នះមារបានត្រាស់
នាំមកនូវសុខវិសេសខ្លាំងណាស់ គ្រប់ព្រះអង្គត្រាស់ព្រះធម៌ទេសនា។
វិសាខបុណ្ណមីថ្ងៃប្រពៃពិត យើងខ្ញុំមានចិត្តនឹងធឹងជ្រះថ្លា
វន្ទាសំពះអង្គព្រះសាស្ដា សូត្រធម៌ថ្វាយផ្កាបូជាប្រទីប ។

*ដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស*

# អាសាឡ្ហបូជា

អាសាឡ្ហបូជា យើងខ្ញុំគ្រប់គ្នា ជ្រះថ្លាកន្លង
ថ្ងៃពេញបូណ៌មី យាយតាប្អូនបង នាំគ្នាត្រសង
មកកាន់អារាម ។

ថ្ងៃនេះអស្ចារ្យ ហេតុប្រាំប្រការ ថ្ងៃចេញចាកកាម
បរិស័ទទាំងអស់ គ្រប់វត្តអារាម នាំគ្នាព្យាយាម
គោរពបូជា ។

**ទីមួយជាថ្ងៃ** ពោធិសត្វថ្លៃ ចាប់ផ្ទៃមាតា
បដិសន្ធិ ក្នុងថ្ងៃនេះណា ដែលផ្ទៃពសុធា
កក្រើកញាប់ញ័រ ។

**ទីពីរជាថ្ងៃ** ព្រះចមម្កុដថ្លៃ និស្សំយបវរ
ចេញសាងព្រះផ្នួស ឲ្យបានដឹងធម៌ ឆ្លងកាត់នគរ
អស់ចំនួនបី ។

**ទីបីនោះណា** ថ្ងៃមហាអស្ចារ្យ អង្គមានសិរី
ត្រាស់បានពីរខែ ទ្រង់យាងឃ្មាតខ្មី យាងទៅកាន់ព្រៃ
ឥសិមិគទា ។

សម្តែងធម្មចក្ក ធម៌ល្អឥតអាក់ បឋមទេសនា
ប្រោសបញ្ចវគ្គិយ នឹងពួកទេវតា មានទាំងព្រហ្មា
យ៉ាងច្រើនអនេក ។

**ទីបួនជាថ្ងៃ** សង្ឃលើផែនដី បានកើតជាឯក

| | | |
|---|---|---|
| កំណើតព្រះសង្ឃ | នឹកឃើញគួរត្រេក | អរយ៉ាងពន់ពេក |
| | នៅក្នុងសន្ដាន ។ | |
| **ទីប្រាំជាថ្ងៃ** | អង្គព្រះជិនស្រី | ព្រះទ័យក្លាហាន |
| សម្ដែងឫទ្ធី | គ្មានអ្នកតាំងបាន | ឫទ្ធិដ៏ថ្កើងថ្កាន |
| | យមកប្បាដិហារ្យ ។ | |
| ផ្ចាញ់ពួកនិគ្រន្ថ | ទដ្ឋិទម្រន់ | អួតអាងអស្ចារ្យ |
| ជាអ្នកយល់ខុស | មិនមានបញ្ញា | ដោយអាងខ្លួនថា |
| | ប្រសើរពេកក្រៃ ។ | |
| បន្ទាប់ពីនោះ | ព្រះភក្ត្រត្រង់ឆ្ពោះ | គិតក្នុងហឫទ័យ |
| ប្រោសពុទ្ធមាតា | នៅស្ថានប្រពៃ | តាវត្តិង្សនោះនៃ |
| | ដោយអភិធម្ម ។ | |
| យើងខ្ញុំគ្រប់គ្នា | គោរពវន្ទា | ដោយចិត្តមនោរម្យ |
| កាយវាចាចិត្ត | គិតគន់ឧត្ដម | ចំពោះបរម |
| | ជាសាស្ដាចារ្យ ។ | |
| ព្រះពុទ្ធព្រះធម៌ | ព្រះសង្ឃបវរ | ខ្ញុំសូមបូជា |
| នូវទៀននិងធូប | ទាំងគ្រឿងសក្ការ | មានភ្ញីមានផ្កា |
| | ព្រមទាំងទឹកអប់ ។ | |
| បូជាកាយចិត្ត | ប្រព្រឹត្តសុចរិត | ឲ្យបានគ្រប់សព្វ |
| បានជាប្រយោជន៍ | ដល់ជនគួរគាប់ | ទេវតាគន្ធព្វ |
| | គ្រប់ភពគ្រប់ស្ថាន ។ | |
| ដោយបុណ្យកុសល | ដែលបានតម្កល់ | នៅក្នុងសន្ដាន |

សូមមនុស្សគ្រប់គ្នា បានសុខក្សេមក្សាន្ត សាងល្អគ្រប់ប្រាណ
កុំបីធ្វើបាប ។
បុណ្យនាំឲ្យរស់ បុណ្យនាំឲ្យខ្ពស់ បុណ្យនាំឲ្យជ្រាប
បុណ្យនាំឲ្យល្អ ឲ្យដឹងខ្ពស់ទាប បុណ្យឲ្យសុភាព
បុណ្យឲ្យសុខស្ងប់ ៕

# គោតមប្រវត្តិថ្មី

- ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្ដាដ៏មានបុណ្យ
  និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន ។
- មកចាប់ផ្ទៃមាតា ស្រីស្រឹង្គារស្រស់កល្យាណ
  កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
- ក្នុងថ្ងៃព្រហស្បតិ៍អា- សាឍមាសាពេញបូណ៌មី
  រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។
- កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
  នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។
- កក្រើកផែនពសុធា មានទេវតារាប់រយពាន់
  ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។

❖ ឆ្នាំចពិសាខនា ថ្ងៃសុក្រជាពេញបូណ៌មី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។
❖ កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកស្នួយ អភិសេកនឹងស្រីង្គារ ។
❖ នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។
❖ កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាឍពេញបូណ៌មី ក្សត្រាថ្លៃបានសុខា ។
❖ ស្ដេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លៃ
គួរឲ្យព្រះរាជា ស្ដេចជំពាក់ចិត្តពេកក្រៃ ។
❖ តែទ្រង់បានកាត់ផ្ដាច់ ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។
❖ បើបិតាបានត្រាស់ រិលរហ័សរកបុត្រា
មកប្រោសស្ងួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។
❖ កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី
អាសាឍពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា ។
❖ កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្ករកិរិយា គ្មាននណាធ្វើដូចអី ។

❖ បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
ជាថ្ងៃព្រះជិនស្រី មានសិរីឈ្នះក្រុងមារ ។
❖ ត្រាស់ដឹងបានពីរខែ ទ្រង់គ្នាន់គ្នេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្ដាលដងព្រឹក្សព្រៃ ។
❖ គឺក្នុងឆ្នាំរកា អាសាឍមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្ដើមពោលស្ដីធម៌ទេសនា ។
❖ ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្ដា មានរហូតដល់សព្វថ្ងៃ ។
❖ នាថ្ងៃមួយនោះណា គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ ។
❖ គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ ។
❖ បីខែកន្លងទៅ មិនឈប់នៅយឺនយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។
❖ គឺក្នុងឆ្នាំនោះឯង មានការផ្សេងតែមាសា
គឺខែពិសាខនា ថ្ងៃអង្គារពេញបូណ៌មី ។
❖ ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍
នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្ដា ។
❖ សូមឲ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។

❖ សូមជួបព្រះសិរអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ផ្ទុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ៕

*និពន្ធដោយ ព្រះភិក្ខុ **វជិរប្បញ្ញោ សាន សុជា***

# គោតមប្រវត្តិ ( បុរាណ )

សូមថ្លែងកាលអង្គព្រះលោកនាថ នាមព្រះសិទ្ធត្ថពង្សពុទ្ធា
ជាម្ចាស់នៃយើងទាំងអស់គ្នា កាលគ្រងយរាកបិលភស្តុ ។
សោយសុខសម្បត្តិនិងមហេសី ពិម្ពាក្សត្រីរូបល្អស្រស់
ប្រសើរលើសស្រីស្នំទាំងអស់ ប្រកបដោយយសថ្កើងប្រពៃ ។
តាំងពីប្រសូត្ររហូតសោយរាជ្យ ទ្រង់មានអំណាចឫទ្ធិជោគជ័យ
ឥតហេតុអ្វីមួយនាំឲ្យភ័យ កក្រើកព្រះទ័យនៃក្សត្រា ។
លុះដល់ព្រះជន្ម២៩ ទ្រង់ចេញទតសួនព្រៃព្រឹក្សា
ទ្រង់ទតនិម្មិតដែលទេវតា តំណែងកាយាជាមនុស្សចាស់។
មនុស្សឈឺមនុស្សស្លាប់និងបព្វជិត ទតហើយទ្រង់គិតសង្វេគណាស់
ទ្រង់សួរសារថីឆាប់រហ័ស បញ្ជាក់ឲ្យច្បាស់គ្រប់នាទី ។
សារថីក្រាបទូលព្រះចមភព តាមពិតសព្វគ្រប់តាំងអំពី
រូបមនុស្សជរាមនុស្សព្យាធិ ដរាបដល់ទីភេទព្រះសង្ឃ ។
កាលពោធិវង្សទ្រង់សណ្តាប់ សារថីសាសព្វតាមពិតត្រង់
ទ្រង់ភ្ញាកព្រះទ័យឆ្ពោះតម្រង់ ដល់កាយព្រះអង្គនិងពួកសត្វ។
ហើយទ្រង់បន្លឺព្រះឱង្ការ ថាឱ! សង្ខារតែងវិបត្តិ

ជរាព្យាធិចង្រៃក្ដាត់ ធ្វើឲ្យសព្វសត្វលំបាកកាយ។
រីឯមរណៈក៏កាចពិត ធ្វើឲ្យជីវិតសត្វអន្តរាយ
អ្នកផងគេស្មានថាសប្បាយ រាល់រូបរាងកាយក្នុងលោកនេះ។
ឱសឱ! រូបប្រាណមិនបានសុខ ទុក្ខអ្វីក៏ទុក្ខច្រើនដល់ម្ល៉េះ
នៃសារថីអើយបើដូច្នេះ គួរតែគេចវេះកុំអាល័យ ។
ឃើញតែអ្នកបួសទើបសុខណាស់ ត្រាស់ដឹងធម៌ច្បាស់ពិតពេកក្រៃ
សម្លាប់តណ្ហាឲ្យក្សិណក្ស័យ ដល់សឹកមាល័យព្រះនិព្វានហោង ៕

❈❈❈❈

# ខ្ញុំនឹកព្រះណាស់

ខ្ញុំឈរកណ្ដាលទីក្រុងចាស់ ខ្ញុំនឹកព្រះណាស់ពេលព្រលប់
បញ្ចគិរីនៅឃើញគ្រប់ ចិត្តខ្ញុំប្រារព្ធព្រះសាស្ដា ។
ផល្គុនខ្មើតចាស់ចន្ទភ្លឺហើយ ខ្ញុំពុំឃើញឡើយព្រះបិតា
បាត់ស្ងាត់សូន្យអស់អរហន្តា សល់តែសិលានិងព្រៃភ្នំ ។
ហាក់ដូចថ្មីៗ ឥឡូវសោះ ស្រាប់តែបាត់អស់ចាកចោលខ្ញុំ
ខ្ញុំបានត្រឹមតែថ្វាយបង្គំ ដួងចិត្តស្រែយំនឹកសាស្ដា ។
នឹកអើយសែននឹកអង្គព្រះពុទ្ធ ខ្ញុំសូមលំអុតឱនសិរសា
សម្ដែងរៀបរាប់ចារអក្ខរា មគធៈសាស្ដាធ្លាប់អាស្រ័យ ។
ថ្វីដ្បិតរូបកាយស្ដេចយាងបាត់ ធម្មកាយមិនខ្វាត់បិតសព្វថ្ងៃ
អារាធនាអង្គព្រះពុទ្ធថ្លៃ គង់ក្នុងហឫទ័យនៃយើងខ្ញុំ ។

*ដោយលោកគ្រូ **អគ្គបណ្ឌិត ប៊ុត សាវង្ស***

# ព្រះអង្គទ្រង់ប្រសូត

កាលព្រះសិទ្ធត្ថអម្ចាស់ថ្លៃ ស្ដេចចុះចាប់ផ្ទៃនៃព្រះមហា
មាយាទេវីពុទ្ធមាតា នៅឆ្នាំរកាពេញបូណ៌មី ។
នាខែអាសាឍថ្ងៃព្រហស្បតិ៍ ជារាជឱរសនៃព្រះស្រី
សុទ្ធោទនៈរាជម្ចាស់ផែនដី កបិលពស្ដុបុរីរាជសីមា ។
ស្ដេចទ្រង់ប្រសូតចេញចាកផ្ទៃ មាតានៅថ្ងៃសុក្រថ្លៃថ្លា
នាពេញបូណ៌មីវិសាខា ឆ្នាំច នោះណាមានសួស្ដី ។
នៅពេលដែលព្រះវរមាតា យាត្រាចេញពីរាជបុរី
កបិលពស្ដុទៅដើម្បី បង្គំព្រះបិតាមាតា ។
នៅឯទេវទហៈរាជធានី ដល់លុម្ពិនីវ័នថ្លៃថ្លា
ទ្រង់ជ្រកក្រោមម្លប់សាលព្រឹក្សា ទិវាត្រង់ជាក់ទ្រង់ឈឺផ្ទៃ ។
ទ្រង់ឈរតោងមែកព្រឹក្សាសាល អយ្យបុត្តត្រកាលឆោមប្រពៃ
ប្រសូតចាកគភ៌រួសរាន់រ៉ៃ វិស័យអ្នកទេសន៍ចាកធម្មា ។
ប្រសូតភ្លាមឈរដើរឈាងឈាន ប្រាំពីរជំហានព្រះបាទា
ទ្រង់បានបន្លឺព្រះវាចា ថាយើងនេះណាជាចម្បង ។
លើលោកទាំងបីឥតនរណា ផ្ទឹមស្មើអាត្មាយើងជាម្ដង
ជាតិនេះជាជាតិបំផុតហោង យើងនឹងចម្លងសត្វទាំងឡាយ។
ឱ្យឆ្លងដល់ទីដ៏ក្សេមក្សាន្ត ដោយធម្មយានអត្ថបរិយាយ
ឱ្យឆ្លងដល់ត្រើយនិព្វាននាយ សូន្យឆ្ងាយចាកទុក្ខសុខមហិមា។
ទីទ្រង់ត្រាស់ដឹងនោះព្រះបាទ អសោកនាថស្ដេចឥណ្ឌា

ទ្រង់សាងគោលថ្មល្អសោភា មួយជាអនុស្សាវរីយ៍ ។
ខ្ញុំសូមក្រាបថ្វាយបង្គំស្មោះ ចំពោះអង្គព្រះមហាមុនី
ស្ដេចទ្រង់ប្រសូតនៅត្រង់ទី សួនលុម្ពិនីដោយសទ្ធា ។
សូមឱ្យសិរីជយមង្គល ចូលដល់ខ្ញុំនិងអ្នករាល់គ្នា
ដែលបានសូធ្យស្ដាប់សព្វពណ៌នា ពុទ្ធប្បវត្តិនេះកុំបីខានឡើយ ៕

*ចាកជំនួយសតិធាតុទី ១៨*

# ព្រះអង្គទ្រង់ត្រាស់ដឹង

កាលព្រះសិទ្ធត្ថដ៏មានបុណ្យ ព្រះជន្មដប់ប្រាំមួយវស្សា
ទ្រង់សោយរាជ្យជួសព្រះបិតា គ្រប់គ្រងរដ្ឋាកបិលពស្ដុ ។
ជាមួយព្រះនាងយសោធរា ពិម្ពាក្សត្រីស្រីល្អស្រស់
ប្រសើរលើសស្រីស្នំទាំងអស់ ប្រកបដោយសច្ចើងណាស់ណា ។
លុះដល់ព្រះជន្មបានគ្រប់ធួន ម្ភៃប្រាំបួនព្រះវស្សា
ទ្រង់បានឱរសមួយថ្លៃថ្លា នាមថារាហុលល្អប្រិមប្រិយ ។
ក្នុងថ្ងៃរាហុលកើតនោះមិញ ទ្រង់ចេញបព្វជ្ជាដោយឃ្មាតខ្មី
បច្ឆិមបដិបត្តិតឹងពេកក្រៃ ដើម្បីឱ្យឆាប់បានត្រាស់ដឹង ។
ក្រោយពេលទ្រង់លះព្រះកិរិយា ទុក្ករៈនោះណាទ្រង់រំពឹង
មជ្ឈិមបដិបត្តិបានត្រាស់ដឹង ធម៌ថ្លៃឥតថ្លឹងដ៏ក្សេមក្សាន្ត ។
នៅនាថ្ងៃពុធពេញបូណ៌មី ពិសាខរង្សីរកាបាន

ជាសព្វញ្ញុពុទ្ធថ្កើងថ្កាន ព្រះញាណប្រាជ្ញប្រោសផ្លុះលោកា
នៅក្រោមដើមពោធិ៍មានមង្គល នៅត្រង់មណ្ឌលឈ្មោះគយា
ក្បែរឆ្នេរនទីនេរញ្ជរា បានជាគ្រូគ្រប់សព្វភពបី ។
ទីទ្រង់ត្រាស់ដឹងនោះព្រះបាទ អសោកនាថស្តេចផែនដី
ទ្រង់សាងព្រះស្តូបល្អប្រិមប្រិយ សម្គាល់ទីដីទ្រង់ត្រាស់ដឹង ។
ខ្ញុំសូមក្រាបថ្វាយបង្គំវន្ទា ឆ្ពោះព្រះភគវាជាទីពឹង
ព្រះអង្គឈ្នះមារហើយត្រាស់ដឹង សម្លឹងត្រើយនាយនិព្វានពិត។
សូមបុណ្យដែលយើងរួបរួមគ្នា ព្យាយាមពុះពារទាំងឆ្ងាយជិត
ទោះក្តៅ រងា យប់ងងឹត ប្រឹងអស់កាយចិត្តដ្បិតជ្រះថ្លា។
សូមបុណ្យទាំងនេះជួយនាំមុខ ឱ្យឆ្លងផុតទុក្ខដូចប្រាថ្នា
សូមឱ្យបានកើតជាតិណាៗ ជួបទាន់សាសនាព្រះទ្រង់ញាណ។
សូមកុំឱ្យជួបភយន្តរាយ រោគាទាំងឡាយកុំឱ្យមាន
សូមកុំឱ្យជួបការអត់ឃ្លាន រហូតនិព្វានកុំខានឡើយ ៕

*ចាកជំនួយសតិភាគទី ១៨*

# ព្រះពុទ្ធដាក់អាយុសង្ខារ-បរិនិព្វាន

អង្គព្រះទ្រង់ញាណមានតេជះ សម្ដែងប្រាប់ព្រះអានន្ទថា
រទេះដែលចាស់បរទៅណា ទៅបានដោយសារអបឫស្សី។
តថាគតចាស់គ្រាំគ្រាហើយ ម្នាលអានន្ទអើយមានមាំអី
ដូចរទេះចាស់អបឫស្សី វស្សាឆ្នាំថ្មីប៉ែតសិបហើយ ។
ក្រោយព្រះអានន្ទទ្រង់ចេញផុត ពីព្រះសម្ពុទ្ធមិនយូរឡើយ
ក្រោយភត្តាហារថ្ងៃត្រង់ហើយ មារមិនកន្តើយគាល់សាស្ដា ។
ឆ្នាំម្សាញ់ខែមាឃថ្ងៃអាទិត្យ ពេញបូណ៌មីពិតថ្ងៃនោះណា
ព្រះអង្គទ្រង់ដាក់អាយុសង្ខារ ចំពោះមុខមារគ្រានោះឯង ។
នៅនាបាវាលចេតិយ ក្បែរវេសាលីក្រៅកំផែង
កក្រើកធរណីគ្រប់កន្លែង ផ្គរលាន់ខ្ទាត់ខ្ទែងខ្វរអាកាស។
ក្រោយមកភិក្ខុជួបជុំគ្នា អង្គព្រះភគវាទ្រង់បានត្រាស់
សម្ដែងគាថាអស្ចារ្យណាស់ រំលឹកយ៉ាងច្បាស់ត្រាស់ឱវាទ។
*ទ្រង់បានត្រាស់ថាសង្ខារទាំងឡាយ តែងតែអន្តរាយវិនាសខូចខាត
ចូរអ្នកទាំងឡាយកុំបីប្រមាទ ប្រឹងប្រែងសង្វាតឲ្យសម្រេចការ។
ភាជន៍ដែលស្មូនឆ្នាំងដំដុតដោយដី តូចក្ដីធំក្ដីឆៅឆ្អិនយ៉ាងណា
ចុងក្រោយរមែងតែងមានកិរិយា បែកធ្លាយធម្មតានេះជាការពិត ។
យ៉ាងណាជីវិតសព្វសត្វនិករ ក្មេងចាស់មានក្រពាលឬបណ្ឌិត
ចុងក្រោយរមែងតែងតែស្លាប់ពិត បាត់បង់ជីវិតក៏យ៉ាងនោះដែរ ។
ជីវិតតថាគតមានប្រមាណតិច គោរពពាក្យពេចន៍ឥតគេចកែប្រែ
ពីថ្ងៃនេះទៅនៅត្រឹមបីខែ តថាគតត្រូវតែបរិនិពាន្វ ។

បីខែកន្លងយ៉ាងរហ័ស សែនសោកស្ដាយណាស់ព្រះទ្រង់ញាណ
វេលាជិតភ្លឺទ្រង់ចូលឈាន ហើយចូលនិព្វានកណ្ដាលព្រៃ។
ក្នុងខែពិសាខថ្ងៃអង្គារ ឆ្នាំម្សាញ់វេលាចុងរាត្រី
ថ្ងៃដប់ប្រាំកើតពេញបូណ៌មី បរិស័ទប្រុសស្រីជុំត្រៀបត្រា ។
ទីទ្រង់និព្វាននោះតាំងនៅ ក្បែរផ្លូវទៅក្រុងកុសិនារា
រាំងភ្នំមួយគូសាលព្រឹក្សា មានផ្ទាំងសិលានៅចន្លោះ ។
កុំថាឡើយមនុស្សសោយសោកា សូម្បីទេវតាស្ថានទាំងអស់
យំសោកបោកប្រាណស្ដាយស្រណោះ លាន់កក្រើកអស់ភពផែនដី ។
ទីទ្រង់និព្វាននោះឥឡូវ មានស្តូបតាំងនៅល្អប្រិមប្រិយ
សម្គាល់ទីដែលព្រះជិនស្រី និព្វានលើដីកុសិនារា ។
ក្នុងស្តូបមានព្រះបដិមាថ្ម កសាងយ៉ាងល្អគួរជ្រះថ្លា
តំណាងព្រះសពព្រះសាស្ដា ស្ងួកស្ងឹងកាយាសែនអាសូរ ។
អ្នកទៅដល់ពិតចិត្តជិតជាប់ ឃើញដូចព្រះសពនៅជ្រងោ
មានស្បង់ចីវរថ្វាយផ្លាស់ប្ដូរ ទឹកនេត្រាហូរនឹកព្រះអង្គ ។
នឹកហាក់ដូចជានៅថ្មីៗ នឹកព្រះជិនស្រីប្រោសស្រោចស្រង់
នឹកដល់ព្រះធម៌ល្អផូរផង់ នឹកទាំងព្រះសង្ឃអង្គសាវ័ក ។
ចាប់តាំងអំពីថ្ងៃនេះទៅ សូមដើរតាមផ្លូវព្រះអរិយៈ
ក្រោមម្លប់ព្រះធម៌ដ៏ត្រជាក់ ផុតពីអន្ទាក់នៃពួកមារ ។
សូមឲ្យលោកអ្នកបានសូធ្យស្ដាប់ ប្រវត្តិសារសព្វព្រះភគវា
បានសុខចម្រើនគ្រប់ៗគ្នា កុំបីឃ្លាតឃ្លាគ្រោះណាឡើយ ៕

*ដោយឧបាសក គុយ សុធន*

# បារមី ៣០

១ ឥតិបិ ទានបារមី សម្បន្នោ សោ ភគវា
ឥតិបិ ទានឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ ទានបរមត្ថបារមី សម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយទានបារមី ទានឧបបារមី ទានបរមត្ថបារមី ដូច្នេះផង ។

២ ឥតិបិ សីលបារមី សម្បន្នោ សោ ភគវា
ឥតិបិ សីលឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ សីលបរមត្ថបារមី សម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយសីលបារមី សីលឧបបារមី សីលបរមត្ថបារមី ដូច្នេះផង ។

៣ ឥតិបិ នេក្ខម្មបារមី សម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្មឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្មបរមត្ថបារមី សម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយនេក្ខម្មបារមី នេក្ខម្មឧបបារមី នេក្ខម្មបរមត្ថបារមី ដូច្នេះផង ។

៤ ឥតិបិ បញ្ញាបារមី សម្បន្នោ សោ ភគវា
ឥតិបិ បញ្ញាឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ បញ្ញាបរមត្ថបារមី សម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយបញ្ញាបារមី បញ្ញាឧបបារមី បញ្ញាបរមត្ថបារមី ដូច្នេះផង ។

**៥ ឥតិបិ វីរិយបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ វីរិយឧបបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ វីរិយបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយវីរិយបារមី វីរិយឧបបារមី វីរិយបរមត្ថបារមី ដូច្នេះផង ។

**៦ ឥតិបិ ខន្តិបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ ខន្តិឧបបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ ខន្តិបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយខន្តិបារមី ខន្តិឧបបារមី ខន្តិបរមត្ថបារមី ដូច្នេះផង ។

**៧ ឥតិបិ សច្ចបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ សច្ចឧបបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ សច្ចបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយសច្ចបារមី សច្ចឧបបារមី សច្ចបរមត្ថបារមី ដូច្នេះផង ។

**៨ ឥតិបិ អធិដ្ឋានបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ អធិដ្ឋានឧបបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ អធិដ្ឋានបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយអធិដ្ឋានបារមី អធិដ្ឋានឧបបារមី អធិដ្ឋានបរមត្ថបារមី ដូច្នេះផង ។

**៩ ឥតិបិ មេត្តាបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ មេត្តាឧបបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ មេត្តាបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយមេត្តាបារមី មេត្តាឧបបារមី មេត្តាបរមត្ថបារមី ដូច្នេះផង ។

**១០ ឥតិបិ ឧបេក្ខាបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ ឧបេក្ខាឧបបារមី សម្បន្នោ សោ ភគវា**
**ឥតិបិ ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយឧបេក្ខាបារមី ឧបេក្ខាឧបបារមី ឧបេក្ខាបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ សមត្តឹសបារមី សម្បន្នោ សោ ភគវាតិ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយបារមីទាំង ៣០ ដូច្នេះផង ។

# ពុទ្ធជយមង្គល

**ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ**
**គ្រីមេខលំ ឧទិតឃោរសសេនមារំ**
**ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សស្ត្រាវុធនានា ។
ជិះគ្រីមេខលជាតិ កោញ្ជនាទខ្ទរពសុធា
ព្រមដោយមារសេនា ពន្លឹកលន់កងស័ព្ទស៊ាន ។
ដោយធម្មពិធី ទានបារមីជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។
រីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះមារគ្រានោះហោង ។

**មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ**
**ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ**
**ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិននាយកៈ ផ្ចាញ់អាឡវកយក្សឃោរឃៅ
រឹងរូសមិនតាំងនៅ ក្នុងខន្តីគុណសត្យា ។
រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា

ក្រៃលែងក្រុងមារា ក្នុងបឋមសម្ពោធិ ។
ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី
ញ៉ាំងចិត្តអសុរី ឲ្យបង់ព្យុះចុះវន្ទា ។
វីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះអាឡវកយក្ខហោង ។

**នាឡាគិរឹ គជវរំ អតិមត្តភូតំ**
**ទាវគ្គិចក្កមសនីវ សុទារុណន្តំ**
**មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គីរីវរគជា ដ៏ហានក្លាចុះប្រេងព្រេច ។
សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកម្ទេច
មុតដូចចក្រុតពេជ្រ ខ្លាំងដូចកម្មអសនី ។
ដោយព្រះពិធីស្រប់ ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញ៉ាំងដំរីឲ្យជ្រះថ្លា ។
វីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះនាឡាគីរី ។

**ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ**
**ធាវន្តិ យោជនបថង្គុលិមាលវន្តំ**
**ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ**

**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលីមាល៍ មានកម្រងគឺម្រាមដៃ
នៃមនុស្សដែលគាត់កាត់ មកដោតចាក់ជាមាល័យ
អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវងាគ្រវី ដេញព្រះមុនីសាស្ដាចារ្យ
ចម្ងាយផ្លូវកន្តារ កណ្ដាលព្រៃបីយោជនា ។
រីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះអង្គុលីមាល៍ ។

**កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា**
**ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ**
**សន្តេន សោមវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្ត្រីមានគភ៌ចាស់ចើសពោះ ។
យកឈើធ្វើជាកូន ព័ន្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។
រម្ងាប់ពាក្យចណ្ឌាល នាកណ្ដាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី គឺសច្ចំពាក្យសត្យា ។
រីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះសាស្ដាឈ្នះចិញ្ចា ។

**សច្ចំ វិហាយមតិសច្ចកវាទកេតុំ**
**វាទាភិរោបិតមនំ អតិអន្ធភូតំ**
**បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ    រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកជា    និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់    ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ    លើកកម្ពស់ដូចដងទង់ ។
បង្កើតមួងងឹត    ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កំចាត់បង់    ដោយប្រទីបគឺបញ្ញា ។
វីជ័យមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា    ឈ្នះសច្ចកៈនិគ្រន្ថ ។

**នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ**
**បុត្តេន ថេរភុជគេន ទមាបយន្តោ**
**ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនទ្រង់ញាណ    ញុំាងមោគ្គលានមានអំណាច
ឲ្យប្លែងជានាគរាជ    ទៅទូន្មានព្យសន៍ភុជង្គ ។
ឈ្មោះនន្ទោបនន្ទ    ចិត្តមោហន្ធរឿងឫទ្ធិរុង
ទិដ្ឋិកាចទ្រនង់    ទ្រង់ផ្ចាញ់ដោយពិធីឈាន ។

គឺឲ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គលាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា ។
វីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះភគវាឈ្នះនាគហោង ។

**ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ**
**ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ**
**ញាណាគទេន វិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថាអាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដៃកាន់អសិរ្ពិស គឺចិត្តទ្រឹស្តិដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ។
ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា។
វីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ឈ្នះព្រហ្មាឥតមានហ្មង ។

**ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា**
**យោ វាចនោ ទិនទិនេ សរតេ មតន្ទី**
**ហិត្វាន នេកវិវិធានិ ចុបទ្ទវានិ**
**មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។**

**យោ នរោ** ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល

ឧស្សាហ៍សាងទានសីល សូត្ររំលឹកព្រះធម៌ថ្លៃ ។
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំសូត្រសព្វ ៗ ថ្ងៃ កើតមង្គលជានិរន្តរ៍ ។
**សោ នរោ** វីជននោះ បានរំដោះរោគអាសន្ន
ឧបទ្រពអនេកលន់ មានប្រការផ្សេង ៗ ផង ។
នឹកដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្លង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ ។

# ពុទ្ធោ នាគល់ព្រះពោធិព្រឹក្ស

(បិដកលេខ ៦៦, ទំព័រ ២៣៧-២៣៨)

**ពុទ្ធោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ បត្តោ ។**

ពាក្យថា **ពុទ្ធោ** គឺព្រះដ៏មានព្រះភាគអង្គណា ព្រះដ៏មានព្រះភាគអង្គនោះជាព្រះសយម្ភូ ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងមិនមាននូវគ្រូអាចារ្យឡើយ ទ្រង់ត្រាស់ដឹងដោយប្រពៃក្រៃលែងនូវសច្ចៈក្នុងធម៌ទាំងនោះដោយព្រះអង្គឯង ពុំបានស្ដាប់ពីមុនមកឡើយ ព្រះអង្គទ្រង់ដល់នូវសព្វញ្ញុតញាណក្នុងធម៌ទាំងឡាយផង ទ្រង់ដល់នូវភាពជំនាញក្នុងពលៈទាំងឡាយផង ។

**ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ** ពាក្យថា **ពុទ្ធោ** តើ **ពុទ្ធោ** ដោយអត្ថដូចម្ដេច ?

១. **ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំងឡាយ ។

២. **ពោធេតា បជាយាតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គញ៉ាំងពពួកជនឱ្យត្រាស់ដឹងផង ។

៣. **សព្វញ្ញុតាយ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌ទាំងពួង ។

៤. **សព្វធម្មសច្ចាវិនាយ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គឃើញនូវធម៌ទាំងពួងដោយញាណចក្ខុ ។

៥. **អនញ្ញនេយ្យតាយ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមិនមានអ្នកដទៃណាដឹកនាំព្រះអង្គឡើយ ។

៦. **វិកសិតាយ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមាននូវស្មារតីដ៏វិសេស ។

៧. **ខីណាសវសង្ខាតេន ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គដល់នូវការរាប់ថាអស់ទៅនូវអាសវៈ ។

៨. **និរុបក្កិលេសសង្ខាតេន ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គដល់នូវការរាប់ថាមិនមានឧបក្កិលេស ។

៩. **ឯកន្តវីតរាគោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវរាគៈដោយដាច់ខាត ។

១០. **ឯកន្តវីតទោសោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវទោសៈដោយដាច់ខាត ។

១១. **ឯកន្តវីតមោហោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវមោហៈដោយដាច់ខាត ។

១២. **ឯកន្តនិក្កិលេសោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមិនមាននូវកិលេសដោយដាច់ខាត ។

១៣. **ឯកាយនមគ្គំ គតោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គយាងទៅក្នុងផ្លូវតែមួយ ជាផ្លូវទៅកាន់ព្រះនិព្វានបានដល់ សតិប្បដ្ឋាន ៤ ។

១៤. **ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរមួយព្រះអង្គឯង ។

១៥. **អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភត្តា ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គកម្ចាត់បង់នូវការមិនមានបញ្ញាដោយការបាននូវបញ្ញា ។

**ពុទ្ធោតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។**

ព្រះនាម **ពុទ្ធោ** នេះ មិនមែនជាព្រះនាមដែលព្រះមាតាថ្វាយទេ មិនមែនព្រះបិតាថ្វាយទេ មិនមែនបងប្អូនប្រុសថ្វាយទេ មិនមែនបងប្អូនស្រីថ្វាយទេ មិនមែនមិត្តអាមាត្យថ្វាយទេ មិនមែនញាតិសាលោហិតថ្វាយទេ មិនមែនសមណព្រាហ្មណ៍ថ្វាយទេ មិនមែនទេវតាថ្វាយ

ទេ ទ្រង់ព្រះនាម **ពុទ្ធោ** នេះជាវិមោក្ខន្តិកនាម គឺព្រះនាមដែលមានក្នុងទីបំផុត នៃអរហត្តផល របស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះភាគជាសច្ឆិកាបញ្ញត្តិ គឺបញ្ញត្តិព្រោះការជាក់ច្បាស់ក្នុងធម៌ទាំងពួង ដែលបានកើត ព្រមជាមួយនឹងសព្វញ្ញុតញ្ញាណ នៅគល់ព្រះពោធិព្រឹក្ស ។

# ធម្មនិយាម ៣០
# របស់ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ

សូមក្រាបបង្គំប្រណម្យវន្ទា ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា។
**មួយ** រញ្ជួយភពជាតិគ្រប់ចុងក្រោយ បារមីនាំឱ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
**ពីរ** គឺព្រះភក្ត្រវរលក្ខណ៍ក្នុងគភ៌ ស្មិងស្មាធិ៍ក្នុងធម៌បវរកាយា
ព្រះភក្ត្របែរផ្ទុយពីខ្នងមាតា ឆ្ពោះផ្ទៃភ្លឺថ្លាមាតារំពៃ ។
**បី** ឥរិយាបថនៃព្រះមាតា ពេលគ្រប់មាសាសាស្ដាចាកផ្ទៃ
មាតាទ្រង់ឈរខុសស្រីដទៃ ប្រសូតបុត្រថ្លៃហប្ញទ័យជ្រះថ្លា។
**បួន** សួនឧទ្យានទីឋានប្រសូត ក្នុងព្រៃរហូតឈើស្រូតចេញផ្កា
ទេវតានិងមនុស្សថ្វាយសាធុការ ចក្រវាឡបព្វតាខ្ទរខ្ទារអ៊ូអរ ។

**ប្រាំ** ព្រះប្រសូត ចុះស្រូតយាងឈាន ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហានបវរ ទើបបានបន្លឺសីហនាទ ។
**ប្រាំមួយ** ប្រមើលទតមើលនិមិត្ត ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត ចិត្តឥតរវាត យាត្រាចាកផ្ទះ។
**ប្រាំពីរ** ធីរោផ្ដាច់ប្ដូរព្យាយាម ឥតមានទាក់ទាមនាមអ្នកបួស
កំណត់វេលាមិនអាចតិចហួស ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង។
**ប្រាំបី** មហេសីគង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ទើបច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា ។
**ប្រាំបួន** ជួនភ័ព្វទ្រង់ទ្រាប់ស្បូវភ្លាំង ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា ទេពធីតាមារមកគ្រាសាយ័ណ្ហ។
**ដប់** គាប់ហប្ញទ័យអានាបាណៈ បរិកម្មប្រចក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់ ដំណើរជវ័នជាន់ឆ្លងកាមា ។
**ដប់មួយ** ជំនួយពីព្រះបារមី ផ្ចាញ់មារអប្រីយ៍ព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ បរិស័ទជ្រះថ្លាបាចផ្កាអភិសេក។
**ដប់ពីរ** មុនីអង្គទ្រង់សម្រេចញាណ ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពិសាខបុណ្ណមីកើតញាណប្លែកៗ ពោធិញ្ញាណខ្ពស់ឯកក្រើកធរណី។
**ដប់បី** ក្សត្រថ្លៃគង់ក្នុងមហាឋាន វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ
សប្ដាហ៍ឋានមួយលើកស្ទួយស្ថានទី ចេតិយព្រះមុនីប្រាំពីរកន្លែង។

**ដប់បួន** ជូនព្រហ្មជុំអារាធនា សូមព្រះភគវាយាងត្រាស់សម្ដែង
ព្រះធម៌ប្រពៃ វិស័យសូរ្យសែង ទ្រង់ព្រមសម្ដែងដោយព្រហ្មវិហារ។
**ដប់ប្រាំ** ចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក ឥសិបតនៈព្រៃមិគទាយា
ឋានត្រៃរតនៈអាសាឡ្ហបូជា ថ្ងៃព្រះភគវាស្ថាបនាព្រះសង្ឃ។
**ដប់ប្រាំមួយ** ទ្រង់គង់ត្រាស់ឱវាទ បាតិមោក្ខស្អាងស្អាតឱវាទផូរផង់
បេះដូងព្រះធម៌ពន្លឺចតុរង្គ ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី។
**ដប់ប្រាំពីរ** ទ្រង់គង់វត្តជេតពន ប្រោសដល់មហាជននិរន្តរ៍ប្រក្រតី
ទ្រង់យកអរុណជេតពនសួស្ដី ជេតពនជិនស្រីអាស្រ័យជានិច្ច។
**ដប់ប្រាំបី** ទ្រង់សម្ដែងបាដិហារ្យ យមកៈអស្ចារ្យនិគ្រន្ថរត់គេច
នៅក្រុងសាវត្ថីប្រុសស្រីមិនតិច នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា។
**ដប់ប្រាំបួន** ទ្រង់គង់ឋានត្រៃត្រិង្ស ត្រិះរិះរំពឹងថ្លឹងគុណមាតា
សម្ដែងអភិធម្មស័ក្តិសមអស្ចារ្យ ថ្វាយព្រះមាតាសុខាអមតៈ។
**ម្ភៃ** គឺព្រះអង្គទ្រង់ចាកទេវលោក ស្ដេចយាងចុះមកដែនសង្កស្សៈ
មហាជនច្រើនពិតយកចិត្តទុកដាក់ បូជាគារវៈអចលចេតិយ។
**ម្ភៃមួយ** គឺទ្រង់គង់ក្នុងសមាបត្តិ ព្រះញាណស្ងប់ស្ងាត់លះកាត់លោកិយ
អរហត្តផលតម្កល់ប្រក្រតី ឆាប់ក្ដីយូរក្ដីវិស័យពុទ្ធញ្ញាណ។
**ម្ភៃពីរ** ប្រមើលមើលគ្រប់វេនេយ្យ ឧបនិស្ស័យសព្វសត្វដែលមាន
ដោយព្រះករុណាសមាបត្តិញ្ញាណ ត្រួតសត្វកោដិលានមានពីរវារៈ។

**ម្ភៃបី** ទ្រង់លៃវិន័យអាជ្ញា បញ្ញត្តិសិក្ខាតាមការជ្រាបជាក់
មានរឿងកើតមុនខូចគុណសាវ័ក មានហេតុជាក់លាក់ទើបដាក់វិន័យ។
**ម្ភៃបួន** អង្រួនហឫទ័យករុណា ជាតកទេសនាសាស្ដាលកលៃ
ដើមរឿងជាហេតុបង្កើតអត្ថន័យ ជាតកប្រពៃលៃតាមហេតុការណ៍។
**ម្ភៃប្រាំ** ទ្រង់ប្រោសដល់ពួកព្រះញាតិ អង្គព្រះលោកនាថសម្ដែងបាដិហារ្យ
កម្ចាត់មានះព្រះញាតិវង្សា ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស។
**ម្ភៃប្រាំមួយ**ទ្រង់គង់ធ្ងន់ក្នុងធម៌ បរិស័ទណាល្អមានធម៌ទ្រទ្រង់
ស្ដេចយាងទទួលស្រុះស្រួលដោយអង្គ គារវៈផូរផង់ឆ្ពោះត្រង់ព្រះធម៌។
**ម្ភៃប្រាំពីរ** ទ្រង់គង់ចាំវស្សា បើមាននរណានិមន្តដោយល្អ
ពេលចេញវស្សាមុនយាងចេញចរ ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះ។
**ម្ភៃប្រាំបី** ទ្រង់គង់យ៉ាងហ្មត់ចត់ មុនភត្តក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ចគ្រប់យាមទាំងអស់ ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតា។
**ម្ភៃប្រាំបួន** ទ្រង់គង់សោយមំសៈ ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា
បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា សោយរសមំសាហឫទ័យបរិសុទ្ធ។
**សាមសិប** អវសានទ្រង់បានចូលឈានមុននឹងនិព្វានឈានច្រើនបំផុត
ម្ភៃប្រាំបួនសែនកោដិសមាបត្តិបរិសុទ្ធ រួចហើយទ្រង់ផុតរលត់សង្ខារ។
**អហំ** វីខ្ញុំ បង្គំវន្ទា ឆ្ពោះព្រះភគវា ព្រះធម៌ថ្លៃថ្លា
ព្រមទាំងព្រះសង្ឃផូរផង់សីលា ចិន្ដាលំអុតព្រះពុទ្ធនិយាម ។

សូមឱ្យសព្វសត្វបដិបត្តិតាមធម៌ សាសនាបវរល្អដូចព្រះនាម
អរហំសម្មាគ្មានការទាក់ទាម កិលេសរវាមរវាតសូន្យបង់ ។
សូមឱ្យសាសនាសម្មាសម្ពុទ្ធ បរិស័ទមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចិរកាលអភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខា។
សូមមនុស្សទេវតាមានការគោរព ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនា
សូមបានសម្រេចដូចក្ដីប្រាថ្នា អស់នូវតណ្ហាទុក្ខាចប់ហោង៕

*ដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស*

# ឧបមាគុណព្រះរតនត្រៃ ២២ ប្រការ

រីគុណព្រះត្រៃរតន៍ បរិសុទ្ធប្រសើរក្រៃ
លោកបានឧបមេយ្យ មានម្ភៃពីរប្រការ ។
⭑**ទីមួយ**គឺព្រះពុទ្ធ ប្រសើរផុតត្រៃលោកា
ប្រៀបបានព្រះចន្ទ្រា រះនាថ្ងៃពេញបូណ៌មី ។
រីឯព្រះធម្មា ប្រៀបដូចជាកាំរស្មី
នៃដួងព្រះច័ន្ទថ្លៃ ចាំងរស្មីភ្លឺលោកា ។
ព្រះសង្ឃដូចលោកហ្នឹង បានទីពឹងព្រោះចន្ទ្រា
ថែងចាំងរស្មីថ្លា ឱ្យលោកាល្អពេកក្រៃ ។

✯ **ទីពីរ**ព្រះភគវា ប្រៀបដូចជាអាទិត្យថ្លៃ
រះឡើងនៅពេលថ្ងៃ មានរស្មីខ្លាំងមហិមា ។
ព្រះធម៌នៃព្រះអង្គ ផូរផង់ដូចអាភា
ចេញពីអាទិត្យថ្លា ដេញអន្ធការឱ្យខ្ចាត់ទៅ ។
ព្រះសង្ឃអង្គសាវ័ក មានសំវរៈល្អពេកកូវ
ដូចទ្វីបលោកដែលត្រូវ អាទិត្យក្ដៅឱ្យភ្លឺថ្លា ។
✯ **ទីបី**ព្រះមុនី ឥតមានពីរក្នុងលោកា
ព្រះអង្គប្រៀបដូចជា អ្នកអុជភ្លើងឆួលដុតព្រៃ ។
រីអង្គព្រះធម្មា ប្រៀបដូចជាភ្លើងក្ដៅក្រៃ
ដុតព្រៃស្មៅចង្រៃ ជាសត្រូវនឹងស្រូវស្រែ ។
ព្រះសង្ឃនោះឯងនៃ ឧបមេយ្យដូចដីស្រែ
ដែលម្ចាស់ខិតខំថែ ក្លាយជាស្រែដ៏ឧត្តម ។
✯ **ទីបួន**ព្រះភគវា ប្រៀបដូចជាភ្លៀងយ៉ាងធំ
ប្រយោជន៍ដ៏ឧត្ដម តែងកើតមានដល់លោកា ។
ព្រះធម៌ព្រះទ្រង់ញាណ ដែលទ្រង់បានប្រោសទេសនា
ដូចដំណក់ទឹកថ្លា ស្រោចដណ្ដប់លើផែនដី ។
សាវ័កអ្នកហ្មត់ចត់ ដូចជនបទពណ៌ខៀវខ្ចី
ដែលភ្លៀងទើបធ្លាក់ថ្មី គួរប្រុសស្រីទាក់នេត្រា ។

| | |
|---|---|
| ⭑**ទីប្រាំ**ព្រះសម្ពុទ្ធ | ប្រសើរផុតជននានា |
| ព្រះអង្គប្រៀបដូចជា | សារថីដ៏ចំណាប់ ។ |
| រីឯព្រះធម៌ថ្លៃ | ឧបមេយ្យដូចជាច្បាប់ |
| ឧបាយជាគ្រឿងចាប់ | បង្វឹកសេះអាជានេយ្យ ។ |
| ព្រះសង្ឃដ៏សោភា | ប្រៀបដូចជាអាជានេយ្យ |
| ហ្វឹកហាត់ល្អប្រពៃ | អាចលៃប្រើទាន់ចិន្ដា ។ |
| ⭑**ប្រាំមួយ**នោះឯងនៃ | ល្អពេកក្រៃព្រះសាស្ដា |
| ព្រះអង្គប្រៀបដូចជា | សល្យពេទ្យសម្រាប់ដកសរ ។ |
| ព្រះធម៌នៃព្រះអង្គ | មានបែបទ្រង់សែនបវរ |
| ដូចឧបាយដកសរ | គឺទិដ្ឋិសត្វគ្រប់គ្នា ។ |
| សង្ឃសាវ័កកល្យាណ | លោកប្រៀបបាននឹងអ្នកណា |
| ដែលសរមុតកាយា | ត្រូវគ្រូពេទ្យដកចេញបាន ។ |
| ⭑**ប្រាំពីរ**ព្រះសម្ពុទ្ធ | បរិសុទ្ធប្រៀបស្មើបាន |
| ចក្ខុពេទ្យចំណាន | ចេះឧបាយបកនេត្រា ។ |
| ព្រះធម៌វិសេសថ្លៃ | ឧបមេយ្យឧបាយា |
| បកភ្នែកជននានា | ឱ្យភ្លឺថ្លាផុតជំងឺ ។ |
| រីឯព្រះសង្ឃា | ប្រៀបដូចជាអ្នកភ្នែកឈឺ |
| ត្រូវពេទ្យបកឱ្យភ្លឺ | ចាកងងឹតគឺមោហា ។ |

⭑**ប្រាំបី**ព្រះភគវន្ត អរហន្តជាសាស្តា
ព្រះអង្គប្រៀបដូចជា ពេទ្យមានប្រាជ្ញាឆ្លាតវៃ។
ព្រះធម៌ដ៏កល្យាណ ប្រៀបស្មើបានឱសថថ្លៃ
ដែលពេទ្យមានស្នាដៃ ច្នៃផ្សំត្រូវយ៉ាងចំណាន ។
ព្រះសង្ឃរតន៍ថ្លៃ ឧបមេយ្យអ្នកដែលបាន
សះស្បើយរោគសាមាន្យ គឺកិលេសគ្រប់ប្រការ ។
⭑**ប្រាំបួន**ព្រះទ្រង់ញាណ ប្រៀបអ្នកបានស្គាល់មាគ៌ា
បង្ហាញសត្វគ្រប់គ្នា ឱ្យទៅរកទីផុតភ័យ ។
រីឯព្រះធម្មា ដែលសាស្តាទ្រង់លកលៃ
ត្រាស់ទុកដល់សព្វថ្ងៃ ឧបមេយ្យផ្លូវសុខា ។
ចំពោះព្រះសង្ឃរតន៍ បរិសុទ្ធឥតមាយា
ប្រៀបដូចប្រុសស្រីណា ដើរដល់ទីដែលក្សេមក្សាន្ត ។
⭑**ទីដប់**ព្រះសាស្តា មានបញ្ញារុងរឿងថ្កាន
ប្រៀបដូចព្រៃហេមពាន្ត ពេញទៅដោយដើមរុក្ខា ។
ព្រះធម៌ដូចដើមថ្នាំ ដុះប្រចាំគ្រប់វេលា
គុណភាពល្អអស្ចារ្យ នៅក្នុងទីព្រៃហេមពាន្ត ។
ព្រះសង្ឃល្អសោភា ប្រៀបដូចជាអ្នកដែលបាន
ឱសថព្រៃហេមពាន្ត ផឹករួចហើយស្បើយរោគា ។

| | |
|---|---|
| ⭑**ដប់មួយ**ព្រះមានជោគ | ដូចនាយទូកក្នុងជលសា |
| តែងមានចិត្តករុណា | ដល់សព្វសត្វក្នុងភពត្រៃ ។ |
| ព្រះធម៌ពាក្យទូន្មាន | ប្រៀបស្មើបានទូកចរណៃ |
| ចម្លងផុតលោកត្រៃ | ឱ្យដល់ត្រើយបានសុខា ។ |
| ព្រះសង្ឃដ៏និមល | ដូចអ្នកដល់ត្រើយហើយណា |
| ត្រើយនោះមានឈ្មោះថា | ព្រះនិព្វានសែនសុខក្រៃ ។ |
| ⭑**ដប់ពីរ**ព្រះភគវា | ជាសាស្តាបញ្ញាវៃ |
| ព្រះអង្គឧបមេយ្យ | អ្នកឱ្យទ្រព្យគាប់ចិន្តា |
| ព្រះធម៌ទាំងប៉ុន្មាន | ប្រៀបស្មើបានទ្រព្យនោះណា។ |
| ដែលជនផងនានា | តែងប្រាថ្នារៀងរាល់ថ្ងៃ ។ |
| សង្ឃសាវ័កកល្យាណ | ដូចអ្នកបានចាយទ្រព្យថ្លៃ |
| គុណភាពល្អពេកក្រៃ | ចាយរួចបានសុខគួរគាប់ ។ |
| ⭑**ដប់បី**ព្រះនិរភ័យ | ឧបមេយ្យអ្នកមានភ័ព្វ |
| បង្ហាញរណ្តៅទ្រព្យ | ឱ្យដល់អ្នកដែលត្រូវការ ។ |
| ព្រះធម៌ពាក្យប្រដៅ | ដូចរណ្តៅទ្រព្យនោះណា |
| ពេញដោយទ្រព្យនានា | មានតម្លៃហួសការស្មាន ។ |
| ព្រះសង្ឃអ្នកស្តាប់ទ្រង់ | ផ្លូវផង់រុងរឿងថ្កាន |
| ប្រៀបដូចជាអ្នកបាន | រណ្តៅទ្រព្យរីករាយក្រៃ ។ |

☆**ដប់បួន**ព្រះចមភព ល្អសព្វគ្រប់គ្មានទោសពៃរ៍
ព្រះអង្គប្រសើរក្រៃ ដូចជាវីរៈបុរស ។
ព្រះធម៌ពាក្យបង្រៀន ប្រៀបស្មើបានក្ដីផុតគ្រោះ
ក្សេមក្សាន្តឥតមានមោះ មានតែសុខគ្រប់ប្រការ ។
ព្រះសង្ឃដ៏សមទ្រង់ វិសុទ្ធិវង្សចិញ្ចៀងថ្លា
ដូចអ្នកបានសុខា ដោយសារវីរៈបុរស ។
☆**ដប់ប្រាំ**ព្រះសម្ពុទ្ធ បរិសុទ្ធសមទាំងអស់
ប្រៀបដូចជាសប្បុរស អ្នកលួងលោមឱ្យបានស្បើយ។
រីព្រះសទ្ធម្មា ប្រៀបដូចការលួងនោះហើយ
លួងលោមឱ្យបានល្ហើយ ស្បើយក្ដីសោករោគចង្រៃ ។
ព្រះសង្ឃសាវ័កពុទ្ធ ដូចអ្នកផុតរួចចាកភ័យ
ឧបទ្រពកំណាចក្រៃ ព្រោះស្នាដៃនៃព្រះអង្គ ។
☆**ដប់ប្រាំមួយ**នោះណា ព្រះសាស្ដាវិសុទ្ធិវង្ស
ព្រះទ័យស្អាតសោះត្រង់ ប្រៀបប្រដូចនឹងមិត្តល្អ ។
រីឯពាក្យទេសនា រចនាជាបទធម៌
ដូចពាក្យមិត្តបវរ ប្រាប់ប្រយោជន៍ដល់មិត្តភ្វា ។
ព្រះសង្ឃឧត្តមពិត អ្នកនៃបនិត្យព្រះធម្មា
ប្រៀបដូចនឹងអ្នកណា បានប្រយោជន៍គាប់ហប្ញទ័យ។

| | |
|---|---|
| ⭑**ដប់ប្រាំពីរ**ព្រះនិរទុក្ខ | ល្អគ្រប់មុខហួសវិស័យ |
| ព្រះអង្គឧបមេយ្យ | បឹងកើតទ្រព្យច្រើនប្រការ ។ |
| ព្រះធម៌ល្អគួរគាប់ | ដូចជាទ្រព្យមានខ្លឹមសារ |
| កើតក្នុងបឹងនោះណា | ជនត្រូវការកើបយកបាន ។ |
| ព្រះសង្ឃស្វាមីភ័ក្តិ | ប្រៀបដូចអ្នកសំណាងមាន |
| ជួបទ្រព្យបឹងកល្យាណ | រមែងបានក្ដីរីករាយ ។ |
| ⭑**ដប់ប្រាំបី**ព្រះសុគត | ល្អវិសុទ្ធិមិនទន់ជ្រាយ |
| ប្រៀបធៀបអធិប្បាយ | អ្នកភ្ញូតទឹករាជកុមារ ។ |
| បណ្ដាំនៃព្រះអង្គ | សមបែបទ្រង់គ្រប់ប្រការ |
| ប្រៀបដូចនឹងទឹកថ្លា | សម្រាប់ងូតជម្រះកាយ ។ |
| ព្រះសង្ឃប្រៀបដូចជា | រាជកុមារបានសប្បាយ |
| ងូតទឹកត្រជាក់សាយ | ជ្រះអស់ក្អែលពីកាយា ។ |
| ⭑**ដប់ប្រាំបួន**ព្រះជិនស្រី | មានសិរីឈ្នះក្រុងមារ |
| ព្រះអង្គប្រៀបដូចជា | អ្នកធ្វើគ្រឿងប្រដាប់កាយ ។ |
| ព្រះធម៌ពាក្យបណ្ដាំ | ពីរពាន់ប្រាំរយឆ្នាំថ្លាយ |
| ដូចគ្រឿងប្រដាប់កាយ | ពេញនិយមគ្រប់វេលា ។ |
| សាវ័កព្រះទ្រង់ញាណ | ដែលលោកបានស្ដាប់ទេសនា |
| ដូចអ្នកល្អសោភា | ព្រោះអលង្ការធម្មក្ខន្ធ ។ |

| | |
|---|---|
| ⋆**ទីម្ដៃ**នោះឯងណា | ឧបមាព្រះភគវន្ត |
| ដូចគ្នានឹងដើមចន្ទន៍ | ប្រកបក្លិនមានតម្លៃ ។ |
| រីឯព្រះសទ្ធម្ម | ដ៏ឧត្ដមសមប្រពៃ |
| ដូចក្លិនចន្ទន៍ចរណៃ | ដែលប្រុសស្រីគួចប្រាថ្នា ។ |
| សាវ័កអ្នកស្មោះត្រង់ | អ្នកទ្រទ្រង់សីលសិក្ខា |
| ដូចជានរណា | ស្រង់ក្លិនចន្ទន៍ឈ្ងុយពេកពិត។ |
| ⋆**ម្ដៃមួយ**ព្រះបិតា | ជាសាស្ដាទ្រង់មានឫទ្ធិ |
| ដូចផ្ដល់ទឹកអម្រឹត | ដល់កូនស្ងួនទាំងប្រុសស្រី ។ |
| រីព្រះសទ្ធម្មណា | ដែលសាស្ដាពោលស្រដី |
| ទេសនាយ៉ាងឃ្មាតខ្មី | ប្រៀបដូចទឹកអម្រឹតហ្នឹង ។ |
| ព្រះសង្ឃប្រៀបដូចជា | អ្នកកំព្រាឥតទីពឹង |
| បានទឹកអម្រឹតហ្នឹង | មានពំនឹងរួចមកណា ។ |
| ⋆**ម្ដៃពីរ**ព្រះគោតម | ដូចបទុមក្នុងជលសា |
| ស្ងួរសៃងរះកាលណា | រីកសាខាស្រស់ឆើតឆាយ ។ |
| ព្រះធម៌ប្រៀបដូចជា | ទឹកដមផ្កាឈូកទាំងឡាយ |
| គួរស្រូបឥតជិននាយ | មាននៅក្នុងបទុមផ្កា ។ |
| ព្រះសង្ឃអង្គសាវ័ក | អ្នកជឿជាក់ត្រៃសិក្ខា |
| ប្រដូចនឹងភូមរា | បានក្រេបផ្កាក្នុងវារី ។ |

★ឧបមាគុណត្រៃរតន៍ មានប្រាកដម្ដេពីរ
ដែលខ្ញុំខំសម្ដី សូត្រវន្ទីយ៍នមស្ការ ។
សូមឱ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិរអារ្យ ជាសាស្ដាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

*ដោយនិក្ខុ វជិរប្បញ្ញោ សាន សុជា*

# ពុទ្ធកិច្ច ៥ យ៉ាង

គ្រាកាលព្រះសម្ពុទ្ធ ប្រសើរបំផុតដ៏ឧត្ដម
បានត្រាស់ជាបឋម សែសិបប្រាំព្រះវស្សា ។
បំពេញពុទ្ធកិច្ច មិនដែលដាច់វេលាណា
សន្មតឈ្មោះហៅថា ពុទ្ធក្រឹត្យាមានប្រាំយ៉ាង ។
**ទី ១** គឺពេលព្រឹក ដ៏ពន្លឺកពន្លឺស្វាង
ព្រះអង្គស្ដេចទ្រង់យាង ចេញបិណ្ឌបាតប្រោសសព្វសត្វ ។
**ទី ២** រសៀលជ្រេ ព្រះសុរិយេពេលទៀបស្ងាត់
ទេសនាប្រោសសព្វសត្វ មិនកំណត់ថាសត្វណា ។
**ទី ៣** ពេលព្រលប់ ព្រះចមភពត្រៃលោកា

ប្រទានធម៌ទេសនា ឱ្យឱវាទភិក្ខុសង្ឃ ។
**ទី ៤** ពេលអធ្រាត្រ ព្រះលោកនាថទ្រង់ផ្ចិតផ្ចង់
ព្រះទ័យល្អស្មោះត្រង់ ទ្រង់ដោះស្រាយនូវប្រស្នា ។
ផ្សេងៗកើតឡើងពិត នៅក្នុងចិត្តនៃទេវតា
ងឿងឆ្ងល់ធម៌ត្រង់ណា ព្រះសាស្ដាទ្រង់អារកាត់ ។
**ទី ៥** ពេលទៀបភ្លឺ ប្រមើលមើលនិស្ស័យសត្វ
នៅក្នុងសង្សារវដ្ដ ឱ្យប្រាកដគួរសន្ដោស ។
សត្វណាមានសំណាង ព្រះអង្គយាងចេញទៅប្រោស
ប្រទានធម៌ទាបខ្ពស់ ឱ្យទៅតាមឧបនិស្ស័យ ។
ធម៌នេះឈ្មោះហៅថា ពុទ្ធក្រឹត្យាប្រសើរក្រៃ
វិជ្ជាទិវថ្ងៃ នៃព្រះពុទ្ធពីបុរាណ ។
បំពេញឥតនឿយណាយ រៀងរាល់ថ្ងៃមិនដែលខាន
លុះចូលព្រះនិព្វាន ទើបឈប់ខានទាំងអស់ហោង ។
ហៃសាធុជនណា អ្នកប្រាថ្នានឹងប៉ុនប៉ង
ចង់ឃ្លាតពីចំណង ត្រៃលោកនេះពិតប្រាកដ ។
ត្រូវខំរៀនសិក្សា នូវធម៌អាថ៌ដែលជាបទ
ពុទ្ធកិច្ចប្រាំប្រាកដ នេះកំណត់គួរយល់ដឹង ។
ជននោះនឹងស្មើបាន នឹងនាឋានជាទីពឹង
ឬនៅនាលោកហ្នឹង នឹងបានខ្លួនជាអ្នកធំ ។
លើសជនផងទាំងឡាយ សុខសប្បាយដ៏ឧត្ដម
ក្សេមក្សាន្តសុខមនោរម្យ រៀងរួចដល់និព្វានហោង ៕

# រក្សាព្រះត្រៃបិដក

សិក្សាបិដកមត៌កព្រះ មានជ័យជំនះឈ្នះមោហា
គឺជាកុសលផ្ដល់បញ្ញា ឆ្លងវដ្ដសង្សារឆ្ពោះនិព្វាន ។
ដូច្នេះយើងត្រូវថែរក្សា បិដកថ្លៃថ្លាជាធម្មទាន
ព្រះធម្មចេតិយប្រាជ្ញាញាណ សាស្ដាត្រូវមានយើងត្រូវប្រឹង ។
រក្សាបិដកមានគុណក្រៃ លកលៃបែងចែកញែកឱ្យដឹង
ប្រាំពីរប្រការគិតសញ្ជឹង ល្អម្ល៉ឹងប្រឹងថៃខ្មែរមានធម៌ ។
**មួយ** គឺ រក្សាព្រះសាសនា មរតកអស្ចារ្យជាពុទ្ធពរ
ពាក្យពិតពាក្យពុទ្ធសុទ្ធបវរ ចេតិយព្រះធម៌ វិ.សុ.អ.។
**ពីរ** គឺរក្សាព្រះសាស្ដា វិន័យធម៌អាច៌ចារទុកដាក់
ឋិតនៅជាគ្រូដ៏សមសក្តិ ប្រចក្សធម្មាជាសាស្ដា ។
**បី** គឺរក្សាការងារសង្ឃ ទ្រទ្រង់តម្រង់ព្រះសាសនា
សង្គាយនាធម៌វិន័យណា ត្រាស់អស់វស្សាសែសិបប្រាំ ។
**បួន** គឺរក្សាគុណសម្បត្តិ នៃពុទ្ធបរិស័ទចាត់ជាឆ្នាំ
ព្រះធម៌វិន័យព្រះអង្គផ្ដាំ ឋិតច្រើនពាន់ឆ្នាំព្រោះបរិស័ទ ។
**ប្រាំ** គឺរក្សាត្រៃសទ្ធម្ម បរិយត្តិនាំចំបដិបត្តិ
បដិវេធៈជាក់កម្ចាត់ កិលេសបង់បាត់នៅស្ងាត់សន្ដាន ។
**ប្រាំមួយ** រក្សាត្រៃរតនៈ ឋិតនៅប្រចក្សសរណដ្ឋាន
ព្រះពុទ្ធព្រះធម៌នាំសុខសាន្ត ព្រះសង្ឃកល្យាណមានវិន័យ។
**ប្រាំពីរ** រក្សាត្រៃសិក្ខា សាសនាចារជាប់ដួងហឫទ័យ

សីលសមាធិធម៌ប្រពៃ ផុតភ័យអាស្រ័យដោយបញ្ញា ។
ព្រះត្រៃបិដកមានប្រវត្តិ រឿងរ៉ាវបានកត់ចារអក្ខរា
អរិយធម៌វប្បធម៌មនុស្សទេវតា បុព្វយ៉ាងណាចារឱ្យដឹង ។
បិដកជាច្បាប់ប្រាប់ភពត្រៃ អ្នកមាននិស្ស័យលៃលកប្រឹង
សិក្សាបដិបត្តិកម្ចាត់ខឹង ជញ្ជឹងសម្លឹងដឹងត្រៃលក្ខណ៍ ។
បិដកច្បាប់ដើមព្រះសាសនា បាលីអក្ខរាសាស្ដាជាក់
បដិបត្តិបូជាធានាមគ្គ កំណត់ត្រៃលក្ខណ៍លាត្រៃលោក។
កសាងចេតិយបិដកខ្មែរ យើងនាំគ្នាហែព្រះមានជោគ
សាធុ ! សាធុ ! ផុតចាករោគ សាធុផុតលោកអនុមោទនា៕

✲✲✲◎◎◎◎✲✲✲✲

# ការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ

ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះអរិយសង្ឃជាទីពឹងទីរលឹក ។ ខ្ញុំព្រះករុណាសូមក្រាបនមស្ការបូជាព្រះគុណនៃអង្គព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ពេញពោរទៅដោយព្រះមេត្តាករុណារកប្រមាណមិនបាន ។ ព្រះអង្គទ្រង់លះបង់គ្រប់យ៉ាងក្នុងការសន្សំព្រះ-បារមីដើម្បីត្រាស់ដឹង ហើយប្រកាសធម៌នាំវេនេយ្យសត្វចេញចាកពីវដ្តៈ។ ខ្ញុំព្រះករុណាបូជាព្រះពុទ្ធចេតិយដោយសេចក្ដីជ្រះថ្លាដ៏ក្រៃលែង សូមតាំងសច្ចាធិដ្ឋាន ដោយផលានិសង្សនៃបុណ្យដែលខ្ញុំព្រះករុណាបានធ្វើក្នុងថ្ងៃនេះ សូមជាបច្ច័យឱ្យបានសម្រេចដូចក្ដីប្រាថ្នា ។ អង្គ

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ធម៌យ៉ាងណា សូមឱ្យខ្ញុំព្រះករុណាមានចំណែកនៃធម៌របស់ព្រះអង្គក្នុងកាលដ៏សមគួរផងចុះ ។ ទោះបីកើតក្នុងភពជាតិណាៗ សូមកើតនៅក្រោមម្លប់នៃបវរព្រះពុទ្ធសាសនាកណ្ដាលកល្យាណមិត្តបានសេពគប់នឹងសប្បុរសដែលជាអ្នកដឹងនូវធម៌ដ៏ប្រសើរ សូមជាបុគ្គលសម្មាទិដ្ឋិ មានឱកាសសិក្សាធម៌ ស្ដាប់ធម៌ ប្រព្រឹត្តធម៌ ដែលជាបច្ច័យឱ្យចម្រើនទៅដោយសតិនឹងបញ្ញា បញ្ជូនតទៅគ្រប់ជាតិរហូតដល់ព្រះនិព្វានហោង ៕

# បណាមគាថា

អរហន្តតថាគត ជ្រាបគ្រប់បទស្វែងគុណធំ
ទ្រង់ជាលោកុត្តម ច្បងជាងសព្វគ្រូលើសលន់ ។
ជាសាស្ដានៃលោក ចេះឥតស្មោកទូន្មានជន
ខ្ញុំវន្ទាបន្ទន់ ទ្រង់ដែលជនគួរបូជា ។
ព្រះធម៌នៃសាស្ដា ឧបមាដូចពន្លឺ
តែងធ្វើលោកឲ្យភ្លឺ ចាក់ងងឹតឲ្យសូន្យផុត ។
ដែលប្រាជ្ញសម្គាល់អាង ថាតំណាងសព្វញ្ញុពុទ្ធ
ខ្ញុំវន្ទាលំអុត ធម៌នោះសុទ្ធបូជា ។
សាវ័កព្រះសុគត ស្អាតហ្មត់ចត់វិសេសថ្លា

ប្រាថ្នាត្រៃសិក្ខា លោកសិក្សាធម៌ឧត្ដម ។
ជាសង្ឃថ្នាក់ខាងលើ មិនអើពើលោកធម្ម
ខ្ញុំវន្ទាប្រណម្យ សង្ឃឧត្ដមជនបូជា ។
ដោយអំណាចវន្ទា ត្រៃរតនាជាអម្ចាស់
សូមឲ្យពុទ្ធសាសន៍ លូតលាស់ក្រាស់ចម្រើនផង។
សូមឲ្យសង្ឃព្រមព្រៀង កុំឲ្យល្មៀងខុសគន្លង
សូមសាធុជនផង កុំមានហ្មងបានសុខសាន្ដ ។
ដោយតេជះត្រៃរតន៍ ខ្ញុំប្រតិបត្តិដោយគោរព
សូមឲ្យការរៀនគ្រប់ របស់ខ្ញុំបានវឌ្ឍនា ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទា
សូមឲ្យការសិក្សា របស់ខ្ញុំបានសម្រេចឆាប់ ។
ដោយអំណាចត្រៃរតន៍ មានពុទ្ធរតន៍ជាប្រធាន
ប្រសិនបើកើតមាន អន្ដធានចង្រៃរោគ ។
សូមឲ្យវិនាសខ្ពោក កុំសល់រោគតិចតួចឡើយ ។

# សុខាភិយាចនគាថា

ព្រះពុទ្ធដូចអាទិត្យ ឧត្ដមពិតជាងពួកជន
កម្ចាត់នូវមោហន្ធ ហើយចេញចាកសព្វកិលេស។
ទ្រង់ស្ថិតនៅលើភ្នំ ដ៏ឧត្ដមមគ្គវិសេស

ដាស់សត្វជាប់កិលេស ឲ្យភ្លឺថែសក្នុងលោកា ។
សូមទ្រង់ប្រោសគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។
ស្វាក្ខាតធម៌ណា ផ្លូវផងថ្លាគ្មានសៅហ្មង
ជាធម៌ដែលអ្នកផង ឃើញច្បាស់ពិតដោយខ្លួនឯង។
ធ្វើនូវសន្តិភាព ផុវភាពដ៏ចិញ្ចែង
គួរបូជាយ៉ាងស្ដែង ធ្វើនិព្វានឲ្យសុខា ។
សូមធម៌នោះគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។
រីព្រះអរិយសង្ឃ ជាបុត្រអង្គព្រះសម្ពុទ្ធ
លោកស្អាតបរិសុទ្ធ ងាយចិញ្ចឹមរៀងរាល់ផ្ទះ ។
ចិញ្ចឹមដោយអាត្មា កិលេសាលះស្រឡះ
សង្គ្រាមក៏លោកលះ ជ្រះស្រឡះបានក្សេមក្សាន្ត ។
ជាអ្នកស្ដាប់ឱវាទ ដែលលោកនាថទ្រង់ទូន្មាន
ជាសាវ័កកល្យាណ ស្រែបុណ្យទាននៃជននា ។
សូមសង្ឃនោះគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។

# សេចក្ដីត្រិះរិះរបស់នាងវិសាខា

សេចក្ដីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានថ្វាយទាន
នូវប្រាសាទថ្មីតាមទ្រព្យដែលមាន ជាវិហារទានចំពោះព្រះសង្ឃ។
សេចក្ដីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានឱនអង្គ
ថ្វាយគ្រែពូកខ្នើយដោយចិត្តផ្ចិតផ្ចង់ ចំពោះដល់សង្ឃដែលគង់ក្នុងវត្ត។
សេចក្ដីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានថ្វាយភត្ត
ផ្សំដោយមំសៈធ្វើដោយហ្មត់ចត់ សលាកភត្តជាអាហារទាន ។
សេចក្ដីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាជួបព្រះទ្រង់ញាណ
ព្រមទាំងព្រះសង្ឃសទ្ធាខ្ញុំមាន ថ្វាយចីវរទានសំពត់សាច់ល្អ។
សេចក្ដីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាជួបសង្ឃបវរ
ថ្វាយភេសជ្ជៈទឹកឃ្មុំប្រេងស្ករ ទឹកដោះគោល្អនិងទឹកអំពៅ។
មកដល់ឥឡូវខ្ញុំបានសម្រេច គ្រប់មុខស្រេចបាច់ឥតមានសល់នៅ
ខ្ញុំបានថ្វាយទានកប់ទុកយ៉ាងជ្រៅ ក្នុងដំណើរទៅកាន់ព្រះនិព្វាន៕

# គុណរបស់ទាន

- **ទាន**ចិញ្ចឹមបុត្របរិសុទ្ធក្នុងផ្ទៃ រហូតដល់ថ្ងៃបុត្រថ្លៃចាកគភ៌
  **ទាន**ចិញ្ចឹមស្មោះទឹកដោះបបរ កូនរស់បានល្អព្រោះធម៌សប្បុរស។
- **ទាន**ថ្វាយដល់សង្ឃផ្ចង់ឧទ្ទិសទាន ប្រេតរួចពីឃ្លានព្រោះទានរំដោះ
  **ទាន**ជាទេវធម៌លម្អសប្បុរស ទានមានចិត្តស្មោះសង្គ្រោះជីវិត។

• **ទាន**គឺជាទ្រព្យជាប់តាមសង្ខាន ជាមិត្តរួមប្រាណឆ្លងភពងងឹត
**ទាន**កាច់បំបាក់មោហៈក្នុងចិត្ត បានត្រាស់ដឹងពិតត្បិតទានបារមី។
• ហៃកូនប្រុសស្រីគប្បីចាំទុក គុណម្ដាយឪពុកទានាធិបតី
កូនដឹងមង្គលសាមសិបប្រាំបី ចៀសកម្មអប្រិយ៍ផុតភ័យអបាយ។

លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

# នមស្ការព្រះរតនត្រៃ

សូមឱ្យសាសនាព្រះសម្ពុទ្ធ រុងរឿងបំផុតអស់កាលយូរ
សូមព្រះសទ្ធម្មព្រះបរមគ្រូ ស្ថិតស្ថេរនៅយូរគ្រប់ប្រាំពាន់
សូមឱ្យព្រះពុទ្ធសាសនា រុងរឿងចម្រើន
សូមឱ្យព្រះពុទ្ធសាសនា ផ្សាយទូទៅពេញសាកលលោក
សូមឱ្យលោកទាំងមូល បានប្រកបដោយសន្តិភាព
ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ**
ពុំមានសេចក្ដីសុខដទៃ ក្រៅអំពីសេចក្ដីស្ងប់ឡើយ ៕

# រាយនាមអ្នកមានសទ្ធាចូលរួមធម្មទាន

- ភិក្ខុចន្ទប្បញ្ញោ អ៊ឹប ភារុណ
- សា.ធម្មសារោ អ៊ឹប សៅរិន
- លោកឪពុកបាច អ៊ឹប និងកូនចៅ

(៣ នាក់ខាងលើ) ២០ក្បាល

- សា. អគ្គធីរោ ប៉ៅ វិសាលនិងអ្នកមានគុណ............៥ក្បាល
- សា.ចន្ទប្បញ្ញោ ចៅ ឆេង..................................៥ក្បាល
- សា.រតនមុនី រេត រិទ្ធ........................................៣ក្បាល
- សា.វិសុទ្ធប្បញ្ញោ ឡយ ផល្លី...........................១០ក្បាល
- សា.វិរប្បញ្ញោ ជារីម វីរៈ..................................៥ក្បាល
- សា.អគ្គប្បញ្ញោ ហ៊ាង រិតី.................................២ក្បាល
- សា.គម្ភីរប្បញ្ញោ រើន កក្កដា..............................៥ក្បាល
- លោក ហេង គង់...........................................៧៥ដុល្លារ
- អ្នកស្រី វ៉ា ស៊ីយ៉ា.........................................៧៥ដុល្លារ
- លោក ហេង វ៉ាពុទ្ធិរាជ....................................២៥ដុល្លារ
- កញ្ញា ហេង វ៉ាសុនីតា.....................................២៥ដុល្លារ
- ឧ.ស. ហេង កៅ.............................................២០ដុល្លារ
- ឧ.សិ. គីម ឆៃប៊ី............................................២៥ដុល្លារ
- លោក អ៊ុង សំណាង(អូ)..........................១០ម៉ឺនរៀល
- លោក គីម សាង.......................................១០ម៉ឺនរៀល
- ឧ.សិ. ជូ ផុនវិជ្ជា..........................................១០ដុល្លារ

- ឧ.សិ. ក្វាច់ គីមសាន..................................១០ដុល្លារ
- ឧ.សិ. ចេង ទូច.........................................១០ដុល្លារ
- ឧ.សិ. វ៉ា សាខន........................................១០ដុល្លារ
- លោក មិុល គុណពិសិដ្ឋ.................................៥ដុល្លារ
- អ្នកស្រី មាស សុជាតិ....................................៥ដុល្លារ
- អ្នកស្រី ញ៉ឹក សុផានី ...................................១០ដុល្លារ
- កញ្ញា រី សុផាន............................................៥ក្បាល
- កញ្ញា រី សុភិន.............................................៥ក្បាល

**យោ បន ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ ។**

*អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អាន បូជានូវព្រះតថាគតដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។*

**សព្វបាបស្ស អករណំ　　កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ　　ឯតំ ពុទ្ធាន សាសនំ ។**

*កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។*

*អកតំ ទុក្កតំ សេយ្យោ　　បច្ឆា តប្បតិ ទុក្កតំ*
*កតញ្ច សុកតំ សេយ្យោ　　យំ កត្វា នានុតប្បតិ ។*

អំពើអាក្រក់ដែលបុគ្គលមិនធ្វើ ប្រសើរជាងព្រោះថា អំពើអាក្រក់រមែងធ្វើឱ្យក្តៅក្រហាយ ក្នុងកាលខាងក្រោយ ។ បុគ្គលធ្វើអំពើណាហើយរមែងមិនក្តៅក្រហាយស្តាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយឈ្មោះថា បុគ្គលប្រសើរ ។